# កម្ពុជសុរិយា

COMMISSION DES MŒURS & COUTUMES

RÉGIE DU DÉPÔT LÉGAL INDOCHINE

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូសុវណ្ណញាណ សួរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


| | | |
|---|---|---|
| **ផ្នែកអក្សរសាស្ត្រ** | | ទំព័រ |
| អ្នកឧកញ៉ាទេពពិទូរឈឹម-ក្រសេម តំណាងក្រសួង | ល្ខោនខោល ... ... | ១៦១ |
| អ្នកឧកញ៉ាវិបុលរាជសេនា(នូ-កាន) តំណាងក្រសួង | រឿងសាមកុក (តមក) ... | ១៧១ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម នៅពុទ្ធសាសនបណ្ឌិត្យ | ប្រវត្តិសាស្ត្រស្រុកចិន (តមក)... | ១៨០ |
| " " | ភូមិសាស្ត្រសកលសង្ខេប (តមក)... | ១៩២ |
| ឃុនសុន្ទរមេធី ញូង-សៀង នៅពុទ្ធសាសនបណ្ឌិត្យ | ឯកសារហស្សរាត្រី ភាគទី១៥ ... | ២០៨ |
| លោក ភិយ-ប៊ុក សមុហបញ្ជី នៅពុទ្ធសាសនបណ្ឌិត្យ | រឿង ស៊ុន-យ៉ាត-សេន (តមក) ... | ២១៩ |
| **ផ្នែកសាសនា** | | |
| សមុហពោធិញាណ ជួង-ធឿន | អំពីការសន្និបាតប្រគល់មុខការព្រះសង្ឃ-យក វត្តឧណ្ណាលោម... ... | ២២៦ |
| ព្រះគ្រូបញ្ញាធិក កៅ-សិម | យុវចរិយកថា (តមក) ... | ២៣២ |


ឆ្នាំទី ១៦ — លេខ ៣ ខែ មីនា ឆ្នាំ ១៩៤៤ — ដំឡៃ៖ ១ ឆ្នាំ ២៨ រៀល ។

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantri NHOK-THÈM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah grū Suvaddhaññāna So-HAY membre de la Commission du Tripitaka

## TABLE DES MATIÈRES

**Partie littéraire :**


| | | page |
|---|---|---|
| Oknha Déb Bidur CHHIM - KRASÉM Député | Danse masquée (Lokhaun khaul). . . | 161 |
| Oknha Vipularājasenā (KARN) Député | Histoire de Sam kok (suite)..... | 171 |
| Luong Nibandhamantri NHOK-THÉM (I.B.) | Histoire de Chine (suite).......... | 189 |
| —id— | Géographie générale (suite)........ | 198 |
| Khun Sundaramedhi NHOUNG - SŒUNG (I.B.) | Mille et une nuits fasc. 15 (suite).... | 208 |
| Monsieur RAY - BUC Chef Comptable (I.B.) | Un épisode de la vie du Dr. Sun-Yat-Sen, (suite)................ | 219 |


**Partie religieuse:**


| | | |
|---|---|---|
| Vén. Samuha Bodhiññāṇa Duong-Dœun Vat d'Unalom P. Penh | Cérémonie de passation de Service du Chef de secte Mahānikāy à Vat d'Unalom Phnom-Penh............ | 225 |
| Vén. Brah grū Paññālikhit KAO - SIM professeur de Pali à l'Ecole supérieure de Pali | Yuvacariyakatha (suite) ........... | 232 |

ល្ខោនខោល

ឧកញ៉ាទេពពិទូរ ក្រសេម គន្ធបណ្ឌិត រៀបរៀង

# អធិប្បាយរឿងល្ខោនខោល

ល្ខោនខោលនេះ ក៏កប់រួមនៅក្នុងពពួកល្ខោនដែរ តែមានចំណាំដោយឡែកផ្សេងអំពីល្ខោន គឺល្ខោននោះគេលេងរឿងផ្សេងៗ មិនមានកំណត់ ចំណែកឯល្ខោនខោលនោះ គេកំណត់លេងចំពោះតែរឿងដែលទាក់ទាមដោយរឿងព្រះជាម្ចាស់ គឺព្រះវិស្ណុ ព្រះនារាយណ៍ ដែលជាព្រះក្នុងសេយ្យសាស្ត្រ គឺលេងរឿងអវតារ (បែងភាគ) របស់ព្រះជាម្ចាស់ ដូចយ៉ាងរឿងរាមកេរ្តិ៍ (រាមាយណៈ) សុទ្ធជាប្រវត្តិរបស់ព្រះជាម្ចាស់នោះ ដើម្បីប្រកាសកិត្តិគុណសេចក្ដីខ្លាំងពូកែនិងឫទ្ធានុភាពរបស់ព្រះជាម្ចាស់ និងអ្នកដែលព្រះជាម្ចាស់បានបែងភាគឲ្យមកកើត ដូចយ៉ាងព្រះរាម, តាមគម្ពីរក្បួនថា លេងរឿងដូច្នេះជាហេតុឲ្យកើតមង្គលសួស្ដីដល់អ្នកលេង និងជាទីប្រោសប្រាណរបស់ព្រះជាម្ចាស់ ទើបគេនិយមលេងមកដល់សព្វថ្ងៃនេះ តែមនុស្សក្នុងសម័យនេះមិនសូវជាមានអ្នកយល់ដូចពោលមកខាងលើនេះទេ គេយល់ត្រឹមតែថាជាមហោស្រព ១ យ៉ាងសម្រាប់លេងជាគ្រឿងសប្បាយរីករាយ ហើយក៏លេងតាមកាលតាមសម័យដែលគួរលេង តាមប្រក្រតីមានលេងតែក្នុងព្រះរាជពិធីធំៗ របស់ស្ដេចផែនដី អ្នកក្រៅមិនដែលឃើញមានលេងទេ ។

រឿងអវតារនោះ មានដល់ទៅ ១០ រឿង, ៩ រឿងខាងដើមជារឿងដែលមានរួចមកហើយ នៅ ១ រឿងខាងចុងបំផុតជា ទឹងមានមកក្នុងអនាគតកាល ក្នុង ១០ រឿងនោះកប់រឿងកមរេក្លួលមួយថាជារឿងព្រះអវតាររឿងនេះក្នុងប្រទេសកម្ពុជាមានគេចេះដឹងដោយច្រើន រឿងឯទៀតជារបស់កំបិតកំបាំង មិនសូវមានអ្នកណាចេះដឹង ហេតុនោះ តែកាលណាត្រូវលេងល្ខោនខោល គេក៏លេងតែរឿងរាមកេរ្តិ៍នោះឯង ក្នុងរឿងនោះមានទាំងមនុស្ស ទាំងយក្ស ទាំងស្វា ៣ សាសន៍ផងគ្នា, ពួកអ្នកលេងអំបាលនោះក៏គោងហាត់ក្បាច់លេងផ្សេងគ្នា តាមភាពរបស់អ្នកទាំង ៣ សាសន៍នោះ គឺអ្នកដែលត្រូវធ្វើជាមនុស្ស (រួមទាំងទេវតាផង) ក៏ហាត់ក៏តាមលំនាំក្បាច់ក្នុងចរិយាទី ២ ដែលពោលមកហើយ អ្នកដែលត្រូវធ្វើជាយក្សនឹងស្វា ក៏ហាត់ក្បាច់ជាភាពយក្សនឹងស្វាផ្សេងទៅទៀតក្បាច់ក៏បែបនេះ មិនដែលប្រទះឃើញក្បួនខ្នាតដើមដែលជាឫសគល់នោះ ៗ ដោយមានដូចម្តេចខ្លះ ប៉ុន្មានបែប ប៉ុន្មានយ៉ាង មិនប្រាកដអ្នកហាត់ក៏គោងតាស្រីយេសិក្សាត ៗ មកដកជដល់សព្វថ្ងៃនេះ តែតាមដែលរួចរួមក្នុងវេលានេះ ឃើញក្បាច់យក្សមាន ..យ៉ាង ក្បាច់ស្វាមាន ... យ៉ាង ដូចមានតទៅនេះ ៗ

# ក្បាច់ល្ខោនខោល ក្បាច់យក្ស

## ក្បាច់ទសកណ្ឋចេញស្តីរាជការទី ១

របៀបបង្គុយ - ទសកណ្ឋទ្រង់គ្រឿងកជ្រពេញយស អង្គុយលុត ជង្គង់លើព្រះវែង ដៃចាំងពីកាន់អាវុធរូបនាគចុងដើម មុខទ្រង់ងើយ ស៊ើងឡើងបន្តិច ជាកិរិយាសំដែងអានុភាពដ៏ឃោរឃៅ ។

## ក្បាច់ទសកណ្ឋចេញស្តីរាជការទី ២

របៀបបង្គុយ - ទសកណ្ឋទ្រង់គ្រឿងដូចមុន អង្គុយបញ្ឈរជង្គង់ខាង ស្តាំ ទំរេតខ្លួនទៅខាងឆ្វេងបន្តិច ដៃស្តាំកាន់អាវុធរូបនាគ ដាក់ដៃគង់ លើជង្គង់ស្តាំ ឲ្យកែងដៃនឹងជង្គង់ស្មើគ្នា, ជាកិរិយាសំចើម ។

## ក្បាច់ទសកណ្ឋចេញស្តីរាជការទី ៣

របៀបបង្គុយ - អង្គុយតាមកិរិយាបថដូចទី ២ ប៉ុន្តែផ្ទៀងក្បាល ទៅខាងស្តាំបន្តិច ដៃកាន់អាវុធដាក់គងលើជង្គង់ស្តាំ ត្រង់ពាក់កណ្តាល កំភួនដៃ ។

## ក្បាច់យក្ស ទី ១

របៀបរាំ - ឈរបោះជើងឆ្វេងទៅមុខយ៉ាងពេញជំហាន បង្អើត មេជើងឲ្យតាំងឡើងលើ ដៃឆ្វេងលើកកបេញទៅមុខ មេដៃបំបត់មក ក្នុងបាតដៃ, ដៃស្តាំដាក់ទៅស្តាំ កាន់អាវុធបញ្ឈរគល់ឡើងលើ ។

## ក្បាច់យក្ខទី ២

របៀបរាំ – ឈរបង់ជំវែងញែកជង្គង់ចេញតាំងសងខាង ចំអែត ខ្លួនចេញទៅស្ដាំខ្លះ ទៅឆ្វេងខ្លះ ដៃស្ដាំកាន់អាវុធពាក់កណ្ដាលលើកឆា ឡើង, ដៃឆ្វេងដាក់ចុះក្រោមចំពត់ខ្លួនដៃចូលក្នុង ក្រោមបង្អុលដៃបង្អុល ចំមកក្បាលឆ្វេងរបស់ខ្លួន ។

## ក្បាច់យក្ខទី ៣

របៀបរាំ – ដូចគ្នានឹងលេខ ២ ប៉ុន្តែដៃឆ្វេងផ្ការបាតដៃចេញ ឲ្យម្រាមដៃចុះក្រោម ។

## ក្បាច់យក្ខទី ៤

របៀបរាំ – ឈរបង់ជំហែងពេញទី ជង្គង់តាំងពីរកាត់ចេញទៅខាង តាំងសងខាង, ដងខ្លួនតាំងត្រង់, ដៃឆ្វេងលើកខ្ពស់ហួសទៅឆ្វេង ផ្ការបាតដៃ ឲ្យម្រាមដៃតាំង ៤ សំយុងចុះក្រោម មេដៃចំពត់ទទឹងបាតដៃ, ដៃឆ្វេងកាន់អាវុធត្រង់ពាក់កណ្ដាលយកមកផ្ទប់នៅពោះ ។

## ក្បាច់យក្ខទី ៥

របៀបរាំ – ឈរបង់ជំហែងពេញទី ជង្គង់តាំងពីរកាត់ចេញទៅឆ្វេង ទៅស្ដាំ ដងខ្លួនទម្រេតផតខាងស្ដាំបន្តិច មុខមើលទៀងទៅឆ្វេង, ដៃ

ឆ្វេងលើកខ្ពស់ ហុចទៅឆ្វេង ដូចក្បាច់ទី ៤, ដៃស្តាំកាន់អាវុធត្រង់ពាក់កណ្តាលឲ្យខាងគល់ឡើងលើ ហើយលាតត្រង់ចេញទៅស្តាំ ។

## ក្បាច់យក្សទី ៦

របៀបរាំ - ឈរបង្ក័ដៃដូចក្បាច់ទី ៨ តែបញ្ឈប់ផ្គង់ជើងឲ្យញោបទៅខាងជើងបន្តិច, ដៃឆ្វេងលើកទៅឆ្វេង តែឲ្យម្រាមទ្រេតមកក្រោយ, ដៃស្តាំកាន់អាវុធត្រង់ពាក់កណ្តាល ឲ្យគល់ចុះក្រោម លើកយោះទៅស្តាំ ។ មុខងើយបែរក្រឡេកមើលឆ្ងាយ ។

### ឧសភាណ្ណចូលឧទ្យាន

របៀបតែងខ្លួន - តែងពេញយសដូចមុន តែគ្មានកាន់អាវុធ ទៅជាកាន់ផ្តិតក្រដាសជំនួស ទីងប្រដាប់ដោយផ្កាក្រងៈនៅដៃស្តាំ ត្រចៀកស្តាំបង់ក្រមាសំយោគផាយទាំងពីរទៅក្រោយ សំដែងកិរិយាសប្បាយរីករាយ ។

### ឧសភាណ្ណរាំ

## ក្បាច់ជជាយ ទី ១

របៀបរាំ - តែងខ្លួនដូចកាលចូលឧទ្យាន តែគ្មានកាន់ផ្តិត, ដំបូងចេញមក ដៃទាំងពីរផ្ទឹមចង្កេះ ។

## ឧសកណ្ដាក់

## ក្បាច់ជដាយ ទី ២

របៀបរាំ- ឈរជាជំហរយក្ខ គឺឈរបង់ដំរែង តែបទោរជន្ទន់ខ្លួន ទៅឆ្វេងបន្តិច ដៃឆ្វេងជីចម្រាមពីរ ដាក់ប្រទល់គ្នានឹងដៃស្ដាំ ពីខាងមុខ ដៃស្ដាំនោះកៀកផ្ចិតផង ។

## ឧសកណ្ដាក់

## ក្បាច់ជដាយទី ៣

របៀបរាំ- ឈរដោយជើងស្ដាំ ជើងឆ្វេងលើកខ្ពស់, ដៃទាំងពីរ លើកហុចត្រង់ទៅមុខ ទឹងជីចម្រាមពីរទាំងសងខាង តែដៃស្ដាំនោះ កៀកផ្ចិតផង ។

## ឧសកណ្ដាក់

## ក្បាច់ជដាយទី ៤

របៀបរាំ- ឈរដោយជើងស្ដាំ បន្ទន់ជង្គង់ទៅមុខបន្តិច, ជើងឆ្វេង លើកខ្ពស់ សំយុងចុងជើងចុះក្រោម ដៃឆ្វេងត្រង់ចេញទៅឆ្វេង ជីចម្រាម ពីរឡើងលើ ម្រាមឯទៀតលាក្រញាងចេញ, ដៃស្ដាំបោះទៅក្រោយ ឲ្យចុងដៃសណ្ដូកចុះតាមបន្តិច ជីចម្រាមពីរ ទឹងកៀកផ្ចិតផង ។

## ធសកាណ្ឌកាំ

# ក្បាច់ជិជាយទី ៥

របៀបរាំ - ឈរឈានជើងឆ្វេងទៅមុខ, ជង្គង់ខ្ទបក្បាលទៅមុខកៀង ឆ្វេងបន្តិច ដៃឆ្វេងធ្វើក្រនុងចេញទៅមុខ ដៃស្តាំបោះទៅក្រោយ តឿត ផ្ចិតបញ្ឆេរឡើង ចាំងរំសាយផ្ចិតឲ្យលាចេញផង(១) ។

## ក្បាច់ក្ងែរូស

របៀបរាំ - ឈរបន្ទន់ជង្គង់ចេញទៅខាង ចុងជើងទាំងពីរកើបបែរ ចេញទៅខាងៗ ដៃទាំងពីរលើកក្រឡឹងចេញទៅ ហើយបំពត់ចុងដៃមកគេខ្លួន, មុខទ្រង់ងើយបន្តិច ក្នុងខណៈនេះ ចង្រ្កាំជើងទាំងពីរផង ។

(វេលានោះក្ងែងនឹងបែបទលេងឲ្យរួស) ។

## ធសកាណ្ឌសោក

របៀបកិរិយាបថ – អង្គុយបត់ជង្គង់ឆ្វេងដាក់ពប បញ្ឈរជង្គង់ស្តាំ ដៃស្តាំដាក់នូងលើជង្គង់ស្តាំ ហើយចាប់ពាន់ដៃឆ្វេង បន្ទន់ក្បាលទៅខាងស្តាំ ធ្វើស្មៀត សំដែងកិរិយាទុក្ខសោក ។ សារ៉ុងដាក់ខាងខ្លួន ។

មេក្បាច់ធំ របស់ក្បាច់យក្ខមាននៃប៉ុណ្ណេះ វេលារាំគេរាំទៅជាលំនាំផ្សេងៗ ដើម្បីភ្ជាប់គពីក្បាច់ ១ ទៅក្បាច់ ១ ត្រង់កន្លែងខ្លះក៏យក

---

១ ផ្ចិតៈផលការនៅផើ មិនជាសំខាន់ប៉ុន្មាន ពេះបំភានការក៏បាន មិនភានក៏បាន ខសំខាន់នៅត្រង់ក្បាច់រាំ ។

ក្បាច់របស់មនុស្សនោះទៅកំផង ត្រង់ចន្លោះដែលសំខាន់ៗទើប
បញ្ចេញក្បាច់បច្ចេកពេញទី ។

☆

☆ ☆

## អធិប្បាយក្បាច់ស្វា

អ្វីដែលត្រូវធ្វើជាស្វា គេតែងខ្លួនទំនងជាស្វា និងពាក់មុខរូបស្វា ជាស្វាសឬស្វាខ្មៅ គេស្លៀកពាក់ពណ៌តាមនោះ បើជាស្តេចស្វា គេមានពាក់សង្វារផង ។

## ក្បាច់ស្វាទី ១

របៀបរាំ - ឈរបង្ខំខែងពេញទី បន្ទន់ជង្គង់ឲ្យញោបទៅខាងមុខបន្តិច ខ្លួនចំអើតចេញទៅមុខចៀនស្តាំ ដៃស្តាំកាន់ការុធខ្លី គឺជាត្រីស្រួល ឬដំបងខ្លី ឲ្យចុងចុះក្រោម ។

## ក្បាច់ស្វា ទី ២

របៀបរាំ — របៀបជំហរដូចទី ១ ប៉ុន្តែដៃឆ្វេងលើកលាតចេញទៅមុខ ហើយបំបត់កដៃចូលមកខាងដើមត្រាមពីរ ដៃស្តាំកាន់ការុធជាក់ពីមុខត្រង់រវាងពោះ បំបត់កដៃចុះក្រោម ឲ្យចុងការុធឡើងលើ តែឲ្យនៅពីក្រៅដៃ ។

## ក្បាច់ស្នាទី ៣

របៀបក៏ — កិរិយាដំហរដូចមុន ប៉ុន្តែដៃឆ្វេងប្រាត់ចុះត្រង់វាង ពាក់កណ្ដាលភ្លៅ ដៃស្ដាំកាន់អាវុធលើកឆាឡើង ឲ្យចុងអាវុធចុះស្រប តាមដៃ ។

## ក្បាច់ស្នាទី ៤

របៀបក៏ - កិរិយាដំហរដូចមុន ប៉ុន្តែដៃឆ្វេងដាក់ផ្កាបចេញទៅមុខ តែឲ្យចុងដៃទាបចុះ ដៃស្ដាំលើកឆាឡើង ឲ្យចុងអាវុធឡើងលើ ។

## ក្បាច់ស្នាទី ៥

របៀបក៏ - កិរិយាដំហរដូចមុន ប៉ុន្តែដៃឆ្វេងលើកខ្ពស់ចេញ ទៅមុខ ម្រាមដៃធ្វើបែបជាមាត់ស្វាហា ។

## ក្បាច់ស្នាទី ៦

របៀបក៏ - កិរិយាដំហរនឹងលើកដៃដូចមុន ប៉ុន្តែតែដៃឆ្វេងបត់ ចូលហើយជីចម្រាមពីរ ។

## ក្បាច់ដើត

របៀបក៏ — ក្បាច់នេះដូចគ្នានឹងក្បាច់ទី ៥ ប៉ុន្តែក្បាច់នេះដៃឆ្វេង ដាក់ត្រង់ស្មើចេញទៅមុខ ។

## ក្បាច់មើលចំហៀង

របៀបរាំ — ឈរវៀចជើងចេញ បញ្ចោកជង្គង់ចេញទៅឆ្វេងទៅស្តាំ ខ្លួនអើត មើលទៅចំហៀងខាងឆ្វេង, ដៃឆ្វេងធ្វើដូចក្បាច់ទី ៥, ដៃស្តាំឈន់កាវុធដាក់ពីមុខភ្នែក ឲ្យពុងចេញទៅក្រៅ ។

## ក្បាច់ស្វាលង់ទ្រនេស

របៀបរាំ - ដើរបន្ទន់ជង្គង់ ដៃឆ្វេងដាក់លើជង្គង់ឆ្វេង ដៃស្តាំយូរឡើង ខ្លួនផ្អៀង បត់បញ្ចៀត ជាកិរិយាអស់កំឡាំងល្ហិតល្ហៃ ។

## ក្បាច់គម្រាម

របៀបរាំ - ជើងឆ្វេងបោះទៅមុខ បញ្ឈរជង្គង់ឡើង ជើងស្តាំសណ្តូកត្រង់ទៅក្រោយ ដៃទាំងពីរដាក់ត្រាប់លើជង្គង់ឆ្វេង ខ្លួនអើតទៅលើជង្គង់ឆ្វេងនោះ ។

## ក្បាច់ធក់

របៀបរាំ — អង្គុយចំគោក ដៃឆ្វេងយូរដាក់ពីមុខ ដៃស្តាំលូកទៅខាងស្តាំខ្លួន, មួលខ្លួនងាកមើលទៅឆ្វេងចៀងខាងក្រោយ ។

## ក្បាច់លប

របៀបរាំ — ជើងឆ្វេងបោះទៅមុខ បញ្ឈរជង្គង់ជើងសណ្តូកទៅក្រោយ បែរមុខចៀងទៅឆ្វេង ដៃទាំងពីរយូរដាក់ពីមុខ ជាការកាស្ទា តែងធ្លាប់ធ្វើដូច្នោះ ។ ចប់ក្បាច់ល្ខោនខោល ។

# រឿងសាមកុក

## វគ្គទី ១

## អ្នកឧកញ៉ាវិបុលរាជសេនា (នូ-កន)

ប្រែពីរឿងសាមកុក ភាសាសៀម

(តមក)

---

គ្រានោះ ស្រុកមេឿងជីវ ៣ ឆឺជីវ ១, ឈិជីវ ១, កេងជីវ១, យ៉ាំង-ជីវ១, គុនជីវ១, ឆឺជីវ១, គិឡូកុនឮ, ពួកអ្នកស្រុកទាំង ៨ តំបន់នេះ ជប់គានសរសេរយក ឈ្មោះតៀវកុកគុកជាទីសក្ការបូជា គ្រប់ៗផ្ទះ, ទើប តៀវកុកប្រើឈ្មោះម៉ាអ្នូនយើឲ្យយកមាសប្រាក់ទៅជូនហាន់ស៊ុខ្ទីដែលជា ចំណាន់ទៃគ្រៃនទូន, ហើយឲ្យម៉ាអ្នូនយើនិយាយជំរាបជាអាថ៌កំបាំងនឹង ហាន់ស៊ុខ្ទីថា "តៀវកុកជូនរបស់នេះមក សុំឲ្យហាន់ស៊ុខ្ទីជួយធ្វើការ ជាកលសឹកក្នុងទីក្រុង" រួចហើយ តៀវកុកក៏ប្រជុំបងប្អូនប្រុសទាំងពីរ នាក់ពន្យល់សេចក្ដីថា "បើនឹងគិតការអ្វីៗ ត្រូវឲ្យយកចិត្តបណ្ដាក្រស្ដ ជាប្រមាណ ដ្បិតឥឡូវនេះបណ្ដាអ្នកស្រុកទាំង ៨ មណ្ឌល ក៏គប់គាន ស្រឡាញ់នៅក្នុងទុកទស្នាបបង្គាប់យើងអស់ហើយ បើបានការព្រម ព្រៀងផ្ដុំគ្នា តទៅយើងត្រូវតែគិតយកផែនដី, ប្រសិនបើយើងមិនធ្វើ តែក្នុងវេលានេះទេ ក៏នឹងមានសេចក្ដីស្ដាយទៅថ្ងៃក្រោយ" ។ ប្អូនប្រុស ទាំងពីរនាក់ក៏យល់ព្រមផង ទើបតៀវកុកឲ្យបញ្ចុះពញ្ញលទ.បាន ព្រម

ដោយត្រៀងសស្ត្រាវុធ ត្រៀមប្រដាប់ការ ដល់កំណត់ចេញច្បាំងវេលា ណា ទើបបានចាត់ការដោយស្រួល ។

តៀវកុកប្រើសិស្សម្នាក់ឈ្មោះគងដីឲ្យនាំសំបុត្រសម្ងាត់យកទៅ ជូនហាន់ស៊ីទីទ្ធី, ឯគងដីវិមិនបានយកសំបុត្រនោះទៅជូនផ្ទាល់ហាន់ស៊ីទីទ្ធី ក៏យកទៅជូននាហ៊ានឯទៀត ឲ្យថ្វាយព្រះចៅឡេនគេវិញ ព្រះចៅ ឡេនគេជ្រាបសេចក្តី ទើបត្រាស់ប្រើឲ្យហោជិនជានាហ៊ានធំលើកគងទ័ព ទៅចាប់ម៉ាអ៊ូនយើដែលជាអ្នកនាំបណ្តាការទៅជូនហាន់ស៊ីទីទ្ធីនោះសម្លាប់ ចោលទៅ ហើយចាប់តាំងហាន់ស៊ីទីទ្ធីដាក់គុកទុកទៀត ។ លុះតៀវកុកដឹង ដំណឹងដូច្នោះ ក៏ចាត់ការត្រៀមសេនាទាហានទុកព្រម, ហើយតាំងខ្លួនជា សៀនកុងបុនគុន (ប្រែថា ស្តេចសួគ៌), តាំងជៀវប៉ោ ប្អូនបង្កាប់ជាតេកុង បុនគុន (ប្រែថា ស្តេចផែនដី), តាំងតៀវលៀង ជាប្អូនពៅ ជាយិនកុង បុនគុន (ប្រែថាស្តេចមនុស្ស), ហើយតៀវកុក ក៏ស្រែកប្រកាសប្រាប់ សេនាទាហានទាំងបណ្តាកស្ត្រទាំងពួងថា រាជការផែនដីនៃព្រះចៅឡេន- គេ ខិនវិនាសសាបសូន្យអស់ហើយៗ មានអ្នកមានបុណ្យមកសោយរាជ- សម្បត្តិជាថ្មីទៀត អ្នកទាំងអស់គ្នាចូរធ្វើតាមពាក្យទេវតាទំនាយចុះទើង បានសេចក្តីសុខសប្បាយដោយមូលមិត្រគ្នា ។ បណ្តាកស្ត្រទាំងពួងឮ ហើយ ក៏មានសេចក្តីត្រេកអរយ៉ាងក្រៃលែង, តៀវកុកឲ្យយកសំពត់ ពណ៌លឿង ជូតក្បាលទាំងអស់គ្នាជាសំគាល់ប្រមាណជាសែសិបប្ហូហា-

សិបម៉ឺននាក់ ដែលជាពួកពលរបស់គៀវកុក, ហើយគៀវកុកនឹងសេនាទាហានទាំងនោះ ក៏ព្រមចិត្តគ្នាធ្វើជាចោរ ទីងតែអ្នកឯណាតទល់នោះគ្មាន ក៏រឹតតែមានកំឡាំងច្រើនឡើង ៗ

ហោជិនឃើញហេតុដូច្នោះ ក៏នាំយកសេចក្ដីនោះទៅក្រាបបង្គំទូលព្រះចៅឡេនតេ ៗ ជ្រាបហើយ ទើបត្រាស់ឲ្យយកព្រះរាជសារប្រាប់ទៅគ្រប់ខេត្តទាំងអស់ថា "បើអ្នកឯណាមានថ្វីដៃខ្លាំងពូកែចាប់ពួកចោរជួតក្បាលលឿងបាន នឹងឲ្យបំណាច់រង្វាន់ធ្វើជានាម៉ឺនមានយសសក្ដិតាមថ្នាក់គុណានុរូប" ទើបត្រាស់ប្រើប៉ុងឡុងជៀវទាហានឯក ១, ឡោជិន ១, ហាន់ហ៊ុស៊ុន ១, ជូហ៊ុ ១, ឲ្យកេណ្ឌពលចេញទៅជា ៣ បែក ដើម្បីព័ទ្ធចាប់ខ្លួនគៀវកុកឲ្យបាន ៗ ឯគៀវកុកក៏លើកទាហានទៅព័ទ្ធលំនៅប៉ុងផែនស្រុក អិវជីវ; ឡោអៀនចៅហ្វាយស្រុកអិវជីវនោះ ជាពួកអ្នកស្រុកកាំងហៃជាប់លោហិតតវង្ស ខឹងហានគូបូ ជាចៅឡាំងប៉ុងហាន់, កាលបើដឹងដំណឹងថា "ពួកចោរជួតក្បាលលឿង លើកគ្នាមកវាយប៉ុងផែនស្រុកអិវជីវដូច្នោះ ក៏ឲ្យហៅចៅចេងជានាយទាហានមកពិគ្រោះប្រឹក្សា, ចៅចេងថា "ពួកចោរមានកំឡាំងក្លាហានណាស់ ទាហានស្រុកយើងតិច គួរឲ្យមានសំបុត្រទៅបញ្ចុះបញ្ចូលពួកអ្នកស្រុក ដែលនៅប៉ុងផែនសិន បើអ្នកឯណាខ្លាំងពូកែមានថ្វីដៃចាប់ពួកចោរទាំងនោះបាននឹងទូលស្នើសេចក្ដីគាប់ប្រសើរនោះដល់ព្រះចៅឡេនតេ" ៗ ឡោអៀនក៏

យល់ព្រម ទើបឲ្យធ្វើជាសំបុត្របញ្ចុះបញ្ចូល យកទៅបិទទុកនៅមុខទ្វារគ្រប់ស្រុកគ្រប់ខែត្រទាំងអស់ ។

នៅស្រុកខុនតួន មានបុរសម្នាក់ឈ្មោះឡៅពី កាលពីកុមារឈ្មោះហៀនតិក ជាអ្នកមិនសូវស្ទាតរៀនសំបុត្រស្នាមអ្វីនឹងគេ តែជាអ្នកបានគប្រិះប្រាជ្ញាច្រើន ចិត្តក៏ល្អ សម្បើមានសេចក្ដីក្រោធយ៉ាងណាក៏មិនអាចនរណាដឹងបាន ព្រោះគ្មានកាការបញ្ចេញទៅខាងក្រៅ ឲ្យគេដឹងប្រាកដសោះ, មានកិរិយាសុភាពរាបសា មានបក្ខពួកច្រើន មានសន្ដានចិត្តជាអ្នកទូលាយ ទាំងរូបកាយសោតក៏ធំជំបងជាងមនុស្សទាំងពួង, ប្រកបដោយលក្ខណរូបធំខ្ពស់ស្រឡះ ប្រមាណជា៨ហត្ថបាយ ត្រចៀកសង់ខាងយារដល់ស្មា ដៃវែងសំយុងចុះក្រោមយារដល់ក្បាលជង្គង់ មុខសក្បុសដូចពណ៌ថ្មកែវ បបូរមាត់ក្រហមដូចជាតិហិង្គុល ភ្នែកទាំងគូបើងាកទៅខាងមើលឃើញត្រចៀកខ្លួនឯង ។

ឡៅពីនោះជាបុត្រឡៅហេង១ជាពូជព្រះវង្សព្រះចៅហាន់កេនះត លុះឡៅហេងជាបិតាអនិច្ចកម្មទៅ ឡៅពីក៏៖នៅកំព្រាតែពីរនាក់នឹងមាតា, ឡៅពីជាមនុស្សមានសេចក្ដីកតញ្ញូ បេះដូងក្លាហានមិនខ្លាចមានហ៊ុន តែជាអ្នកខ្សត់ទ្រព្យសម្បត្តិ ត្បាញកែកន្ទេលលក់ចិញ្ចឹមជីវិត ។ ទីលំនៅដែលឡៅពីនៅនោះឈ្មោះភូមិឡៅសង្ឈុន នៅជិតស្រុកខុន·

ខ្លួន, ផ្ទះដែលទៀពីនៅៗ ជិតជើងមេឃៗ នោះមានកំពស់ប្រមាណជា ៨ ព្យាមព្វាយ មានដែកគ្រសុំសាខាដូចត្រែ ។

គ្រាមួយមានគ្រូម្នាក់ដើរមកឃើញភូមិផ្ទះទៀពីទីដើមមនត្រូវនឹងតម្រាខ្លួន ក៏ទំនាយថា "ភូមិនេះមានអ្នកមានបុណ្យនៅ, វេលានោះទៀពីនៅតូចនៅឡើយ ពេលដែលទៀពីលេងជាមួយនឹងក្មេងតូចៗដូចគ្នាតែងស្រែកថា "បើអញបានធ្វើស្តេច អញនឹងយកដើមមននេះធ្វើជាស្តេចឆត្រប្រាំង" ទៀអ្នកគឺជាមាបានឮទៀពីនិយាយពាក្យដូច្នេះក៏សំគាល់ទៀពីថា "ក្មេងអញនេះប្រហែលជាមានបុណ្យប្រាកដមែន" ចាប់តាំងពីពេលនោះមក ទៀអ្នកគឺជាមាក៏ទំនុកបំរុងឲ្យឆាសប្រាកដល់ទៀពីជារឿយៗ ។ លុះកុមារទៀពីអាយុបាន ១៥ ឆ្នាំ មាតាឲ្យទៅនៅរៀនអក្សរនឹងគ្រូម្នាក់ឈ្មោះគហៀន, ទៀពីមានសំឡាញ់ពីនាក់ឈ្មោះទៀទិត១, ឥនស៊ិនតាន់១, ទៅរៀនអក្សរជាមួយគ្នាដរាបទាល់តែដល់អាយុ ២៥ ឆ្នាំ ។

ខណៈនោះ ទៀពីដើរចេញទៅបានឃើញសិបុត្រដែលគេបិទនៅគ្រានីទ្វារស្រុកក៏ឈរមើលៗ ហើយដកដង្ហើមធំ, ពេលនោះមានមនុស្សម្នាក់ឈរពីក្រោយខ្នងទៀពី ពោលថា "យី! អ្នកឯងនេះជាតិជាប្រុសត្រឡាំង, ម៉េចក៏មិនជួយយកសាសាដែនដី? ហេតុអ្វីហ៊ានមកឈរដកដង្ហើមធំដូច្នេះវិញ" ទៀពីបែរមុខទៅឃើញមនុស្សនោះឈរពីក្រោយ

រូបកន្ទំដំបង កំពស់ ៥ ហត្ថ ក្បាលដូចក្បាលខ្លា ភ្នែកក្រឡោតធំៗ ធ្មេញវែងធំ សំឡេងឮដូចផ្គរ កិរិយាដូចរេះជាយ ៗ ឡៅពីឃើញចំឡែកដូច្នោះ ក៏សួរថា "អ្នកឯងឈ្មោះអី?" មនុស្សនោះឆ្លើយថា "យើងឈ្មោះគៀវហ៊ុយ អេកកិត នៅស្រុកប៊ុនគុន, យើងមានទ្រព្យសម្បត្តិទីងវែងសម្បារជាច្រើន មានចាំងកានលក់ស៊ុកានីងសាប់ទៀតផងយើងគាប់ចិត្តនឹងរកបន់នឹងមិត្រភក្តិណាដែលមានសតិបញ្ញាច្រើន, ឥឡូវនេះ យើងបានមកឃើញអ្នកឈរមើលសំបុត្រហើយដកដង្ហើមធំ នាំឲ្យយើងពិតាល់ក្នុងចិត្តពេកណាស់ ទើបយើងសួរអ្នកបង់ដឹងសេចក្តី ៗ ឡៅពីឆ្លើយថា "យើងជាពូជព្រះវង្សព្រះចៅហាន់គេងតេ ឈ្មោះឡៅពី បានឮដំណឹងថា មានពួកចោរជួតក្បាលលឿងមកធ្វើឲ្យអន្តរាយផែនដី ទើបយើងចង់ជួយយកអាសាផែនដី ចេញទៅកំចាត់ពួកអាចោរទាំងនោះ តែនឹងលុះទៅមិនរួចដោយកំឡាំងតិចទ្រព្យសម្បត្តិក៏ស្តួចស្តើង យើងគិតទៅមិនសម្រេច ទើបឈរដកដង្ហើមធំដូច្នេះ" ។ គៀវហ៊ុយឆ្លើយថា "ទ្រព្យសម្បត្តិយើងឯណោះមានគ្រប់គ្រាន់ល្មមហើយ, ដូច្នេះយើងគិតនាំគ្នាទៅបញ្ចុះបញ្ចូលពួកអ្នកស្រុកដែលមានចិត្តដូចគ្នា ១ ឲ្យលើកគ្នាទៅជួយព័ទ្ធចាប់ពួកចោរកំណាចទាំងនោះ, តើអ្នកយល់ថាដូចម្តេច?" ឡៅពីឆ្លើយថា "គំនិតដែលអ្នកគិតនេះត្រូវពិតមែនហើយ គាប់ចិត្តយើងពេក

ណាស់ ដោយគំនិតនេះត្រូវនឹងគំនិតយើង រួចក៏បបួលគ្នាចូលទៅក្នុង តៀមស្រាទិញស្រាផឹកជាមួយគ្នា ។

ខណៈនោះ មានមនុស្សម្នាក់រូបរាងធាត់ធំសម្បើមបរទេសមកឈប់ នៅមុខតៀមលក់ស្រា ហើយស្រែកហៅអ្នកលក់ស្រាថា "ចូរអ្នកយក ស្រាមកលក់ឲ្យយើងឆាប់ៗ យើងនឹងការផឹករួចទៅជួយយកអាសាផែនដី" ខ្ញុំពីរនាក់ទៅឃើញមនុស្សនោះរូបរាងធំជំបង កំពស់ ៦ ហត្ថ ពុកចង្កាប្រវែង ១ ហត្ថកន្លះ មុខក្រហមដូចផ្លែព្រាំ បបូរមាត់ក្រហមដូច ជាតិហិង្គុល ចិញ្ចើមដូចគូទនាង ( សត្វនាង ) ភ្នែកវែងដូចភ្នែកសត្វគោរើក តិរច្ឆាន ខុសប្លែកពីមនុស្សធម្មតា, ខ្ញុំពីរឃើញដូច្នោះក៏បបួលឲ្យចូលទៅ ផឹកស្រាជាមួយគ្នាហើយសួរថា "អ្នកឈ្មោះអ្វី ?" មនុស្សនោះឆ្លើយថា " យើងឈ្មោះគួនអ៊ូ ខ្លះហៅថាហ៊ុនចៀង, នៅស្រុកហាតុងកៃលៀង នៅស្រុកនោះមានមនុស្សម្នាក់មានទ្រព្យសម្បត្តិច្រើន ប៉ុន្តែកាចណាស់ តែងតែកំហែងមនុស្សទាំងពួងឲ្យគេតោកខ្ទាចខ្លួន, យើងឃើញហេតុ អាក្រក់ដូច្នេះក៏សម្លាប់វាចោលទៅ, យើងរត់មកនៅស្រុកនេះស្រុកនោះ ជាច្រើនឆ្នាំហើយ ឥឡូវយើងទើបនឹងចូលមកដល់ស្រុកនេះបានឮ ដំណឹងថា ខាងគេបិទប្រកាសបញ្ចុះបញ្ចូលពួកអ្នកស្រុកឲ្យទៅជួយយក អាសាផែនដីចាប់ពួកចោរជួតក្បាលលឿង, ហេតុនេះបានជាយើងមក ដើម្បីជួយយកអាសាធ្វើការនេះ ។

ឡៅពីតបថា "មែនហើយ! យើងទាំងពីរនាក់នេះក៏កំពុងតែត្រិះរិះគិតដូចអ្នកដែរ  បើយើងទាំង ៣ នាក់មានគំនិតគិតត្រូវគ្នាដូច្នេះឈ្មោះថាជាការប្រពៃពេកណាស់", កួនអ៊ូបានឮដូច្នោះ  ក៏មានសេចក្ដីពេញចិត្តឥតករន្ទៀស, គៀវហ៊ុយឆ្លើយថា "យើងទាំង ៣  នាក់មានគំនិតគិតត្រូវគ្នាដូច្នេះ  ខ្ញុំសូមអញ្ជើញអ្នកទាំងពីរទៅផ្ទះខ្ញុំ, នៅក្រោយផ្ទះខ្ញុំមានសួនច្បារជាទីសប្បាយណាស់  ហើយជាកន្លែងស្ងាត់ផង  ទាំងផ្កាឈើទៀត ក៏មានរីកនៅទីនោះជាច្រើន  យើងនឹងបានបេះបូជាព្រះឥសូរទេព្ដា ហើយនឹងបានឲ្យសច្ចាប្រណិធានដល់គ្នាឲ្យជាចិត្ត ១ ថ្លើម ១ ជាមួយគ្នា នឹងបានគិតគូរការធំតទៅ ។ ឡៅពីនឹងកួនអ៊ូ បានឮដូច្នោះមានសេចក្ដីត្រេកអរណាស់  ទើបចប់លគ្នា  ដើរតម្រង់ទៅកាន់ផ្ទះគៀវហ៊ុយ ។

ព្រឹកឡើងគៀវហ៊ុយក៏រៀបចាត់ចែងយកសេះសនឹងក្របីខ្មៅនូវធូបទៀន  មានទាំងគ្រឿងពិធីការអាមិសផ្សេងៗ នាំយកទៅជាមួយផង, លុះទៅដល់ទីសួនច្បារក្រោយផ្ទះ  ក៏អុជទៀនធូបធ្វើសក្ការបូជាព្រះឥសូរទេព្ដា កាន់សច្ចាប្រណិធានថា ×"យើងខ្ញុំឈ្មោះឡៅពី, កួនអ៊ូ, គៀវហ៊ុយ ទាំង ៣ នាក់នេះ  នៅស្រុកទេសផ្សេងៗពីគ្នា  វេលាថ្ងៃនេះបានមកគប់ប្រសព្វគ្នា,  យើងនឹងបានកាន់ចិត្តឲ្យសត្យសញ្ញាដោយសច្ចាប្រណិធានស្បថស្បានសុំយកគ្នាធ្វើជាបងប្អូន បាក់ដូចជាបងប្អូនរួមឧទរជាមួយគ្នាជាចិត្តជីវិត ១  សុំឲ្យមានសេចក្ដីទៀងត្រង់ដល់គ្នានឹងគ្នាត្រា

តែអស់ជីវិតទៀតខ្លួន ដើម្បីនឹងបានជួយទំនុកបំរុងផែនដីឲ្យបានសេចក្តីសុខតទៅ, បើមានភ័យអន្តរាយដោយប្រការឯណាមួយ ត្រូវឲ្យជួយយកអាសាដល់គ្នានឹងគ្នា សូម្បីមានឧបក្រ័យក្នុងសឹកសង្គ្រាមក្តីក៏មិនលះបង់ចោលគ្នាឡើយ គឺត្រូវតែជួយការពារគ្នារហូតដល់តែស្លាប់ទាំង ៣ នាក់. រីសេចក្តីសច្ចៈដែលយើងខ្ញុំទាំង ៣ នាក់បានតាំងសច្ចាប្រណិធាននេះ យើងខ្ញុំសូមទុកចិត្តចំពោះមុខទេវតា សូមឲ្យទេវតាជួយធ្វើជាសាក្សីពេជ្រញាណ បើតទៅយើងខ្ញុំទាំង ៣ នាក់ពុំទៀងត្រង់នឹងគ្នា សូមឲ្យទេវតាបំផ្លាញជីវិតឲ្យឃើញពិតប្រាកដទាន់នៃភ្នែកនាលោកិយ ។

លុះធ្វើសច្ចាប្រណិធានរួចហើយ គេក៏សន្មតហៅឡៅពីជាបងបង្អស់, គួនអ៊ីជាប្អូនបន្ទាប់, តៀវហ៊ុយជាប្អូនពៅ ។ វេលានោះពួកអ្នកស្រុកដែលខ្លាំងពូកែ ពួកណាបានដឹង ក៏នាំគ្នាទៅចុះចូលនឹងពួកនេះបានប្រមាណជា ៣០០ នាក់ ។

ថ្ងៃមួយឡៅពី, គួនអ៊ី, តៀវហ៊ុយបានឲ្យរៀបតុលៀងភោជនាហារ ចាត់ការរៀបចំគ្រឿងសស្ត្រាវុធទុកជាស្រេច នៅខ្វះតែសេះជិះប៉ុណ្ណោះដែលមិនទាន់មាន ។

ក្រោយពេលនោះបន្តិចមក ស្រាប់តែមានបុរសម្នាក់មកប្រាប់ឡៅពីថា "ឥឡូវនេះមានឈ្មួញពីរនាក់នាំសេះជាច្រើនចូលមកលក់ក្នុងស្រុកនេះ ឡៅពីឮដូច្នោះក៏ស្ទុះម៉ាចេញទៅទទួលឈ្មួញសេះទាំងពីរនាក់

នោះនាំចូលមក ឯឈ្មួញសេះទាំងពីរនោះ ម្នាក់ឈ្មោះតៀវស៊ីផេង, ម្នាក់ទៀតឈ្មោះឡៅស៊ុង, ឈ្មួញទាំងពីរនាក់នេះបាននិយាយប្រាប់ឡៅពីថា "យើងខ្ញុំទាំងពីរនាក់រកស៊ីជួញសេះបានសុខជាយូរឆ្នាំមកហើយ ទើបតែមកដល់ឆ្នាំនេះ នាំសេះទៅលក់ប្រទះតែនឹងពួកចោរ នៅកណ្ដាលផ្លូវទៅមិនរួច, ទើបយើងខ្ញុំនាំគ្នាត្រឡប់ចូលមកស្រុកនេះវិញ" ។ ឡៅពីស្ដាប់ហើយក៏ហៅឈ្មួញទាំងពីរនាក់នោះឡើងទៅលើផ្ទះ ហើយបង្គាប់ឲ្យរៀបចំភោជនាហារ បរិភោគទាំងអស់គ្នា រួចទើបឡៅពីផ្ដើមនិយាយឡើងថា យើងគិតនាំគ្នាទៅចាប់ពួកចោរកំណាច ដែលក៏ធ្វើឲ្យចលាចលដល់ផែនដី ។ តៀវស៊ីផេងនឹងឡៅស៊ុងស្ដាប់ហើយឆ្លើយថា "លោកមានប្រាថ្នានេះត្រូវនឹងបំណងរបស់យើងខ្ញុំពេកណាស់ ដូច្នេះយើងខ្ញុំទាំងពីរនាក់សូមជូនសេះ ៥០, ប្រាក់ ៥០០ ដំឡឹងនិងដែក ១០០ ហាបដល់លោក ដើម្បីជាកំឡាំងធ្វើការនេះតទៅ, ថាហើយក៏ជូនរបស់ទាំងនោះទៅឲ្យឡៅពី ។ បានទទួលហើយ មានសេចក្ដីត្រេកអរគុណដល់ឈ្មួញទាំងពីរនាក់ជាអនេក, រួចទើបឲ្យគេជាងមកដំធ្វើដាវត្របី ២ សម្រាប់កាន់ខ្លួនឯង, ដំធ្វើដាវផាវខ ១ ប្រវែង ១១ ហត្ថ ទម្ងន់ ៨២ នាឡិ ឲ្យកួនអ៊ូកាន់ ដំធ្វើលំពែង ១ ប្រវែង ១០ ហត្ថ ទម្ងន់ ៨៥ នាឡិ ឲ្យតៀវហ៊ុយកាន់ ហើយនិងឲ្យធ្វើគ្រឿងក្រោះពាក់ និងអានសេះសម្រាប់បញ្ចូលគ្រប់គ្នាទាំង ៣ នាក់ ។

ចាប់តាំងពីពេលនោះមក អ្នកតាំង ៣ នាក់ក៏បញ្ចុះបញ្ចូលពួកអ្នកស្រុកដែលមានរង្វៃបានចំនួន ៥០០ នាក់នាំគ្នាលួចទៅគេហៅថង ក៏នាំគ្នាទៅគេហៅហ្វាយស្រុកឡៅអៀន អ្នកតាំង ៣ នាក់តាំងខ្លួនជាហ្វាយស្រុករួចហើយ ទើបនិយាយប្រាប់ឈ្មោះទីដែលស្នាក់នៅហ្វាយស្រុកឡៅអៀន ៗ ព្រួចឡៅពីសែជាមួយគ្នា ក៏មានសេចក្ដីមេត្រីចំពោះឡៅពីជាខ្លាំង, ទើបទទួលឡៅពីទុកជាកូនប្រុស ។

លុះនៅមកបានច្រើនថ្ងៃ មានបំរើនាំសំបុត្រពួកមកប្រាប់ថា "ពួកចោរជួតក្បាលលឿង មានទាហានឯកឈ្មោះគៀស៊ួនជី បានលើកពលចំនួន ៧ ម៉ឺននាក់ ទន្ទ្រានចូលមកដល់ក្នុងដែនស្រុកខ្ញុំហើយ" ហ្វាយស្រុកឡៅអៀនព្រួចចោះ ក៏ចាត់ទៅបង្ហាញ ឡៅពី, គួនអ៊ូ, តៀហ៊ុយមកប្រាប់ថា "អ្នកតាំង ៣ នាក់! ចូរអ្នកនាំគ្នាលើកទ័ពចំនួន ៥០០ នាក់ ទៅតទល់ចាប់ពួកចោរទាំងនោះឲ្យបាន" អ្នកតាំង ៣ នាក់បានព្រួចចោះមានចិត្តត្រេកអរណាស់ ព្រមទទួលជួយយកអាសាដែនដី ទើបលើកកងទ័ពទាំង ៥០០ ចេញសំដៅទៅកាន់ភ្នំថៃហៀងសាន មើលទៅក៏ឃើញពួកចោរដើរដេរដាស លើកគ្នាចូលមកជាច្រើន ឯពួកចោរទាំងនោះមិនបួងសក់ទេ ស្លៀកសំយាកសក់ ហើយជួតក្បាលសំពត់ពណ៌លឿងទាំងអស់គ្នា ឡៅពីឃើញចោះ ក៏ឲ្យរៀបចំជាបន្ទាយកយចំរូងស្រាសបន្ទា ផ្ដាក់ផែនពួកចុះវិញ ហើយបរសេះចេញទៅឈរមុខ

ទំព   ឲ្យកូនអ៊ុំជិះសេះតាមខាងស្ដាំ   ឲ្យគៀវហ៊ុយជិះសេះតាមខាងឆ្វេង ទៀវព៉ាក៏លើកសេនាទៀនបង្គុំមុខកាបោរ ហើយជេរថា "នែអាពួកក្បត់" ។ មេទ័ពគៀវអួនជី ក្ដីទៀវព៉ាជេរដូច្នោះខឹងណាស់ ទើបប្រាប់ពាហានឯកម្នាក់ ឈ្មោះគេងមៅឲ្យទៀនជិះសេះចេញទៅតយុទ្ធនាកណ្ដាលរណរង្គ គៀវ-ហ៊ុយកាន់លំពែងប្រវែង ១០ ហត្ថ បរសេះចូលទៅប្រយុទ្ធនឹងគេងមៅក្ដាម ពេលនោះគៀវហ៊ុយកាំភ្លើងលំពែង   ចាក់ត្រូវចំពាក់កណ្ដាលដើមទ្រូង គេងមៅធ្លាក់ពីលើខ្នងសេះស្លាប់ក្នុងខណៈនោះឯង ។

*** គៀវអួនជីខឹងខ្លាំងណាស់ ស្ទុះកាន់ដាវទៀនសេះបរសំដៅគៀវហ៊ុយ កូនអ៊ុំឃើញដូច្នោះ ក៏ស្ទុះទៀនសេះបរទៅពាំងពីមុខគៀវហ៊ុយទាំងទទួលវង់ គៀវអួនជីឃើញរូបកូនអ៊ុំ ក៏ស្លុតស្មារតីភ័យរលះរលាំង កូនអ៊ុំឃើញបានការក៏យកដាវកាប់ត្រូវខ្នងគៀវអួនជីដាច់ជាពីរកំណាត់ ពួកបោរទាំងឡាយក៏បែកខ្ចាត់ខ្ចាយរត់ចេញទៅអស់ ទៀវព៉ាក៏បរពលចូលដេញប្រ-កាប់ចាប់ពួកទាហានបានជាឈ្លើយច្រើនណាស់ លុះមានជ័យជំនះហើយ ក៏លើកពលវិលត្រឡប់មកស្រុកខុនគួនវិញ ។

ឯទៀវអៀនលុះដឹងពាណិតមាន ក៏ចេញទៅទទួលទៀវព៉ាដល់ទ្វារស្រុកហើយនាំត្រឡប់ចូលមក ទៀវអៀនក៏ឲ្យបំណាច់រង្វាន់ដល់ពួកទា-ហានតាមសមគួរ លុះព្រឹកឡើង មានបំរើសេះកាន់សំបុត្រសិបកេងហៅ-ហ្វាយស្រុកគេងជី មកដល់ហៅហ្វាយស្រុកខុនគួនថា ឥឡូវនេះពួក

ហៅផ្ទួតក្បាលល្បឿន លើកទ័ពមកពីស្រុកចេងជីវច្រើនណាស់ សុំឲ្យ
ហៅហ៊្វាយស្រុកខុនគួនលើកទ័ពទៅជួយ ឡេវអៀនជីងជូហោះក៏ឲ្យហៅ
ឡេវពីមកប្រឹក្សា ឡេវពីថាខ្ញុំបាទទីងជួន ២ នាក់សុំយកកាសាចេញ
ទៅជួយស្រុកចេងជីវឲ្យអស់ពីចិត្ត ។ ឡេវអៀនបានស្តាប់ក៏ជាប់ចិត្តត្រេក
អរណាស់ស្រះស្រាំងតាំងឲ្យហៅចេងឃុំនាំពលទាហាន ៥.០០០ លើក
ចេញទៅជាមួយនឹងឡេវពីកួនអ៊ូ តៀវហ៊ុយ ឡេវពីនឹងហៅចេងលើក
ទាហានទៅដល់ស្រុកចេងជីវ ពួកចោរឃើញធង់ទ័ពក៏លើកត្រឡប់មក
ហោមវាយ ។

ឡេវពីហៅចេងមានពលទាហានតិច ក៏ការថយគេចមកហើយ
ប្រឹក្សាគ្នានឹងកួនអ៊ូ តៀវហ៊ុយថា ពលទាហានយើងតិចជាងពួកចោរ
យើងត្រូវគិតជាកលសឹក ទើបមានជ័យជំនះងាយ ថាហើយឡេវពីឲ្យកួនអ៊ូ
ឃុំនាំពលទាហាន ១ ពាន់ ទៅបង្កប់នៅតំបន់ភ្នំខាងស្តាំផ្លូវ ឲ្យតៀវហ៊ុយ
ឃុំនាំពលទាហាន ១ ពាន់ទៅបង្កប់នៅខាងឆ្វេងផ្លូវ កំណត់ថា បើបានឮ
សំឡេងឃ្មោះវេលាណា ឲ្យលើកទាហានវាយខ្ទប់សង្កុញចូលមកទាំង
សងខាង កួនអ៊ូ តៀវហ៊ុយទទួលបង្គាប់ឡេវពីហើយក៏លើកទាហាន
ចេញទៅ លុះព្រឹកឡើងឡេវពីនឹងហៅចេង ក៏លើកទាហានទៅតាមផ្លូវ
ដែលកួនអ៊ូ តៀវហ៊ុយបង្កប់ពលនៅនោះ ។

ឯពួកចោរក៏លើកពលរុកកន្ទ្រានចេញពីគេទៀតពីរកងបរពលចូលប្រយុទ្ធៈហើយកាប់យកទ័ពមកដល់ចែកភ្នំដែលបន្ទប់ទាហាននោះ ហើយឲ្យកំលោះឈ្មោះជាសញ្ញាខ្សែង ក្លែងក្ដី តៀវហ៊ុយ ដែលបន្ទប់ទាហានទាំងសេនាធិការទ្ធហើយ ក៏វក្ខេញទាហានបំពានក្រោយជួបប្រសព្វគ្នាមក ទៀត-ពីក៏ចេញទាហានក្រោយខ្ចប់តម្រុយមកវិញ ។

ទ័ពចោរៈកាហោ ចាលច្របល់គ្នាជាវឹកវរសន្ធឹកណាស់ ស៊ីនកេដ៏ះពានទៅដើរកំផែងស្រុកចេនជ័រ ទ័ពទៀតក៏ ក្លែងស៊ូ តៀវ ហ៊ុយ ក៏ចេញក្រោយប្រសព្វខ្ទប់ពួកចោរ ខានស៊ុំបកេងទៅហ្វាយស្រុកចេនជ័រ ឃើញបានចោរ ក៏លើកទាហានចេញតាមទ្វារស្រុកព្រែកក្រោយក្រស៊ុក ១ ជួរទៀតគ្រប់ទាំង ៤ ទិស ពួកចោរទាំងនោះក៏ស្ទុះរត់ព្រាត់ព្រាយលាយច្របល់គ្នា ក៏មកែត្រូវប្អូសខ្ទីនស្លាប់ក៏គណនាពុំអស់ លុះអស់ពេលយុទ្ធនាការបណ្ដាំធាយកនទ័ពគ្រប់ខ្ទុនក៏លើកពលចូលបន្ទាយវិញ ។

ស៊ុំបកេងទៅហ្វាយស្រុក ក៏បកភ្ជាប់ដល់ពលទាហានទៀតពីតាមសមគួរ ហើយទៅចេនបិយាយថា យើងខ្ទីនលើកទាហានត្រឡប់ទៅស្រុកចុនគួរវិញ ទៀតពីព្រោះថា ខ្ញុំបានឮគេនិយាយថា លោកតជាចីកុងឡូនចៀនជាទាហានឯករបស់ព្រះចៅះឡូនតេ កំពុងច្បាំងនឹងតៀវកុកជាមេចោរ នៅក្រុងស្រុកកុងតុង បើដូច្នេះខ្ញុំនឹងសុំយកអាសាលើកទាហានទៅច្បាំងនឹងពួកចោរនៅទីនោះទៀត ចោរបេនឮដូច្នោះក៏ចាត់ទាហានឲ្យ

ទៀតពី ៨០០ នាក់ ឯចៅបទ៍លើកទាហានដម្រង់ទៅស្រុកចុងគួរវិញ ខណៈនោះទៀតពី គួនមួ គៀ ហើយក៏លើកទាហានទៅដល់ស្រុកគុកកុន ហើយបបួលគ្នាបទៅរកលោចិត ទើបយកទាហានដែលខ្ទមបានត ច្បាំងនឹងពួកចោរកាលគ្រាមុននោះមកពណ៌នាឲ្យលោចិតស្ដាប់ លោចិត ពេញចិត្តណាស់ក៏និយាយថា អ្នកទាំង ៣ នាក់ចូរនៅធ្វើការជាមួយ នឹងយើងចុះ ៗ

ខាងគៀវកុកមានពួកចោរជាពលទាហានចំនួន ១៨ មុឺន ខាងឯ លោចិតមានពលទាហានចំនួន ៨ មុឺន ទ័ព លោចិតនឹងគៀវកុកតាំង បន្ទាយប្រល់គ្នា បានតតាំងច្បាំងគ្នាមិនទាន់ចាញ់ឈ្នះនៅឡើយ លោចិតនិយាយនឹងទៀតពីថា គៀវប៉ូនឹងគៀវពៀងជាប្អូនគៀវកុកនោះ យុំទាំពួកចោរទៅច្បាំងនឹងបាន់ហ៊ូសុនទឹងជូហ៊ុំនៅស្រុកអេងជួ យើង នឹងបំបែកទាហានឲ្យអ្នក ១០០០ ជាមួយនឹងទាហានរបស់អ្នកចូរលើក ទៅជួយបាន់ហ៊ូសុនទឹងជូហ៊ុំនៅស្រុកអេងជួនចុះ ហើយឲ្យអ្នកជួយស៊ើប យកដំណឹងការច្បាំងក្រោលឲ្យដឹងផង ទៀតពីទទួលពាក្យលោចិត ហើយក៏លើកទាហានស្រុកគូតាំងយប់ថ្ងៃដំរង់ទៅស្រុកអេងជួន ៗ

ឯបាន់ហ៊ូសុនទឹងជូហ៊ុំកំពុងតែពេលចូលច្បាំងនឹងទ័ពនោះនៅមិនទាន់ ចាញ់ឈ្នះអស់ពេលហើយ គៀវប៉ូគៀវពៀងឲ្យទាហានចាយទៅកាន់ទី កន្លែង ហើយឲ្យយកបំពង់ធ្វើជារំឡុំក្នុងបន្ទាយ ខាងឯបាន់ហ៊ូសុនទឹង

ដូហ៊ុបានដឹងទើបប្រឹក្សាគ្នាថា ឥឡូវនេះពួកចោរយកចំបើងទៅសង់ធ្វើជំរំក្នុងបន្ទាយ យើងនឹងគិតយកភ្លើងដុតបន្ទាយពួកចោរឲ្យបាន គិតហើយឲ្យយកស្មៅទៅគរលាក់ទុកក្បែរបន្ទាយជាច្រើន លុះពេលកណ្តាលអធ្រាត្រយប់ស្ងាត់ប្រហែលយាម ២ ក៏បង្កើតខ្យល់ព្យុះជាខ្លាំងបោកបក់ត្រឡប់ ពួកទាហានដែលបញ្ជូនទៅលាក់បង្កប់យល់បានការ ក៏នាំគ្នាយកភ្លើងឈូលដុតស្មៅនោះឆេះឡើង ភ្លើងក៏ឆេះរាលដាលអស់ទាំងទីបន្ទាយចោរ ពន្លឺភ្លើងក៏ភ្លឺស្រឡះស្រឡៅបីដូចពេលថ្ងៃ ពួកចោរសឹងតែគិតភ័យជាចលាចលច្រូលច្របល់ក្នុងបន្ទាយ សឹងតែស្ទុះទៅត្រាក់ត្រាយចោលគ្រឿងប្រដាប់សម្រាប់សឹកនឹងក្រោះបំពាក់ទីងកានសេះ ភ្លើងក៏ឆេះឡើងមិនឥតគមានសេសសល់ ពួកចោរតែប្រវល់ចេញពីបន្ទាយ ហាំងហ៊ូស៊ុងនឹងដូហ៊ុក៏តាំងពួយរៀបពួកពលឲ្យចូលដេញតាក់កាប់សម្លាប់ពួកចោរត្រូវរបួសពិការមរណៈស្លាប់នឹងគ្រាប់ពុំបាន លុះព្រឹកឡើងគៀរប៉ូរគៀរ-លៀងគូររស់ពួកចោរអាំងឡាប ដែលនៅសល់នោះសឹងតែដោះតែឲ្យរួចជីវិតតែរៀងខ្លួន លុះតែទៅជួបនឹងកងទ័ពមួយកងសុទ្ធតែកាន់ទង់ក្រហមជានទាហានកងមុខចេញស្ទាក់កាត់ពួកចោរទុកមិនឲ្យទៅមុខបាន ឯមេទ័ពនោះឈ្មោះចូឆូ កំពស់ប្រហែល ៨ ហត្ថកែកត្តូចពុកមាត់វែង ជាបុត្រចូក ។ (បត្តិចូឆូ) រីឯចូឆូនោះ កាលនៅពីក្មេងរមែងចូលចិត្តដើរលេងនៃព្រៃគងបបាញ់សត្វ តែងចូលចិត្តស្តាប់ចម្រៀងរបាំក្បួតគ្រួ

មានសតិបញ្ញាវាងវៃហួស ឈ្មោះចចកព្រៃជាមា កាលបានឃើញចូចជាអ្នកលេងមិនធ្វើការរកស៊ីក៏មានចិត្តស្អប់ខ្ពើមណាស់ ហើយដើរទៅប្រាប្រាជ្ញាទីនប្រាប់រឿងក៏ទៅឲ្យចចកជាបងជីង ចូចជីងថាចចកជាមាស្អប់ខ្លួនក៏រៀងទៅប្រាប់ពិតា ក៏ប្រែក្លាយធ្វើជាខ្យល់តាប់ដួល មាឃើញដូច្នោះក៏ស្រែកប្រាប់ចចកថា ចូចខ្យល់តាប់ដួលទៅហើយ ចចកភ័យណាស់ស្ទុះប្រញាប់ទៅមើល ចូចក៏ក្រោកឡើងលេងដូចប្រក្រតី ចចកក៏សួរថា ឆាឯងទៅប្រាប់អញអម្បាញ់មិញថា ឯងខ្យល់តាប់ ឥឡូវបាត់ហើយឬ? ចូចឆ្លើយថា ខ្ញុំតាំងពីដើមរៀងមកមិនដែលមានឈឺក្បាលសោះឡើយ ហេតុដែលមាគាត់ស្អប់ខ្ញុំបាទណាស់ ទើបយកសេចក្ដីមិនពិតមកដាក់បង្ខិតដោយកែងក្លាយទេ តាំងពីថ្ងៃនេះតទៅចចកក៏ជឿពាក្យចូច ទោះមានោះ ទីងនាំយកហេតុអ្វីទៅនិយាយប្រាប់ក៏ចចកលែងជឿពាក្យសំដីប្អូនសោះ ឯចូចក៏កាន់តែកើបឥតគោតខ្លាចនរណា ប្រព្រឹត្តអំពើអាក្រក់ផ្សេងៗ ជាដើម ពួកក្មេងដែលលេងជាមួយគ្នាក៏លើកបញ្ចោរសរសើរចូចថា ដែនដីសម័យនេះកើតកែវបេលាបលខ្លាំងណាស់ គ្មាននរណាមួយមានសតិបញ្ញាក្លៀវក្លាហ៊ានប្រាជប្រាជ្ញការពារបច្ចាមិត្តឲ្យរាបទាបសោះ យើងទាំងឡាយយល់ឃើញថា ខ្លួនលោកមានសតិបញ្ញា ពេញនិតិការប្រាជប្រាជ្ញពួកគាក់ណាប ក៏អាចនឹងធ្វើឲ្យដែនដីប្រកបដោយសេចក្ដីសុខបាន ។

ឯក្នុងស្រុកឡាំបុងនោះ មានមនុស្សម្នាក់ឈ្មោះ ហុ នៅ មានប្រាជ្ញាជ្រៅជ្រះណាស់ តែងនិយាយឲ្យអ្នកតាំងក្នុងបានដឹងថាផែនដីក្រុងជាពជឈាទី នោះនឹងវិនាសសាបសូន្យហើយ ដែលនឹងប្រោះប្រាមពួកបច្ចាមិត្រភពផសត្រូវឲ្យរាបទាបបាន ឃើញមានតែប្អូនម្នាក់ ។ ឯស្រុកលិចឡាំនោះ មានគ្រូម្នាក់ឈ្មោះខៅគៀវ ចេះមើលលក្ខណៈមនុស្ស លុះប្អូនដឹង ហើយក៏ស្វែងទៅរកខៅគៀវបានជួប ហើយសួរខៅគៀវថា ខ្ញុំខំប្រឹងនេះអំណើះតទៅមុខ តើនឹងបានជាមនុស្សល្អ ឬអាក្រក់ប្រការដូចម្តេច? ខៅគៀវនៅតែស្ងៀម ប្អូនក៏សួរថែមទៅទៀត ខៅគៀវឆ្លើយថា ខ្លួនអ្នកជាមនុស្សមានសតិបញ្ញាក្រៃន តទៅមុខនឹងការពារផែនដីបាន ប៉ុន្តែមិនបានប្រកបដោយសក្យសុចរិតនឹងផែនដី គឺជាស្រុកនៃពជសម្បត្តិ ។ ប្អូនក៏សើចដោយសេចក្តីពេញចិត្ត លុះប្អូនបានអាយុ ២០ ឆ្នាំ ក៏ចូលទៅធ្វើការជាតាហានក្នុងស្រុកឡុកកៀនជាចៅក្រុង ប្អូនឲ្យយកឈើចំរឹង ៨០ កំណាត់ទៅដោតគុកត្រង់ទ្វារទាំង ៤ ទិស ហាមមិនឲ្យមនុស្សដើរកណ្តាលយប់ បើនរណាដើរទៅមកខុសវេលា ឲ្យចាប់ចកខ្លួនទៅធ្វើទោស លុះកណ្តាលយប់ក្នុងថ្ងៃមួយ ប្អូនដើរទៅត្រួតក្រវែលប្រទះនឹងមនុស្សម្នាក់ជាមាពួកខន្ទី ដើរមកខុសវេលា ប្អូនឲ្យចាប់ខ្លួនទៅវាយ ១៥ ខ្ទាប់ ។

(មានត)

# ប្រវត្តិសាស្ត្រសង្ខេបប្រទេសចិន

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

### ប្រែរៀបរៀងអំពីប្រវត្តិសាស្ត្រសាកល

(តមក)

---

ក្នុងឆ្នាំពុទ្ធសករាជ ១២៤៩ ក្រុមតួកដែលឈ្មោះខេប៊ូប៊ីកលើកទ័ពចូលមកលុកលុយស្រុកចានស៊ូ ព្រះនាងមិនបាត់ការតទល់ទេ បណ្ដោយឲ្យខ្មាំងធ្វើលេងបានតាមសប្បាយចិត្ត ។ ក្នុងឆ្នាំពុទ្ធសករាជ ១២៥១ មានព្រះអង្គម្ចាស់មួយអង្គក្នុងរាជវង្សថាំង បានលួចសម្លាប់ វូហានសេ ប្រុសសហាយរបស់ព្រះនាងវ៉ៃ-ជីបង់ ៗ ទើបនាំឲ្យកើតហេតុធំរឿង ព្រះរាជឱរសរបស់ព្រះបាទចុង-សុងដែលជាមកុដរាជកុមារ ត្រាប់តាមថាជាធម្មៈហេតុនៃឃាតកកម្មនេះ ព្រះបាទចុង-សុងមានព្រះឱង្ការឲ្យចាប់ព្រះរាជឱរសរបស់ព្រះអង្គនាំទៅប្រហារជីវិតនៅចំពោះមុខអាមាត្យមន្ត្រីទាំងពួង ព្រោះហេតុតែមានចិត្តក្លាហានហ៊ានសម្លាប់ប្រុសសហាយរបស់ព្រះអគ្គមហេសី ។ ទុកជាព្រះបាទចុង-សុង ព្រះអង្គអំណាចធ្វើតាមចំណង់ចិត្តរបស់ព្រះនាងដល់ម្ល៉េះហើយក៏ដោយក៏នៅតែមិនជាទីគាប់ចិត្តរបស់ព្រះនាងវ៉ៃ-ជីទេ ដល់មកក្នុងឆ្នាំពុទ្ធសករាជ ១២៥៣ ព្រះនាងវ៉ៃ-ជី បានដាក់ថ្នាំបំពុលព្រះរាជស្វាមីរាល់តែទិវង្គតទៅ ដែលជាអំពើគម្រោងក្រក់ក្រៃលែងជាងព្រះនាងវូ-ហៅទៅទៀត ។

មកដល់គ្រានេះ ពួកអាមាត្យមន្ត្រីចិនគង់នឹកស្តាយព្រះនាងវ៉ូ-ហៀវ ព្រោះតាមពិតនោះ ព្រះនាងវ៉ូ-ហៀវ នេះទុកជាលោភសាហាវយ៉ាងណា នៅមានសតិបញ្ញាប៉ិនប្រសប់ខាងការត្រួតត្រាស្រុកទេស មិនបណ្តោយឲ្យខ្មាំងចូលមកញាំញីស្រុកចិនបានតាមចំនើងចិត្ត បើទុកជាព្រះនាងវ៉ូ-ហៀវ បានបំផ្លាញជីវិតមនុស្សជាចំនួនច្រើនមែនតែចំពោះមនុស្សដែលជាសត្រូវនឹងព្រះនាង មិនបានសម្លាប់មនុស្សដែលមានបុណ្យគុណនឹងខ្លួនដូចជាព្រះរាជស្វាមីទេ ។ តាមចំនងនេះឃើញថា ព្រះនាងវ៉ៃ-ជី ជាស្ត្រីកាក្រក់ក្រៃលែងជាងព្រះនាងវ៉ូ-ហៀវទៅទៀត ។

កាលព្រះនាងវ៉ៃ-ជី បានផ្តាច់ផ្តិលព្រះជន្មព្រះរាជស្វាមីហើយ ក៏ចំព្យាយាមបិទបាំងឃាតកម្មដ៏ធំសំបើមនេះ ប៉ុន្តែរឿងនេះបិទមិនជិត បានវែងឆ្ងាយសាយភាយចេញទៅហើយ ពួកមន្ត្រីចាស់ៗ ក៏នាំគ្នាបង្ករការបះបោរឡើង ៗ ឯព្រះនាងវ៉ៃ-ជី មិនមានបញ្ញាឈ្លាសវៃប្រហែលនឹងព្រះនាងវ៉ូ-ហៀវទេ មិនអាចបំបិទបំបាំងទុច្ចរិតកម្មនោះបានផង មិនអាចរម្ងាប់ការបះបោរខាងក្នុងស្រុកបានផង ។ ពេលនោះមានក្សត្រស្រឡាយរាជវង្សយ៉ាងមួយអង្គទ្រង់ព្រះនាម មិង-ហ៊ុង ត្រូវជាពជនត្តារបស់ព្រះបាទ ចុង-សុង កាលបានដឹងដំណឹងឃាតកម្មនោះ ក៏លើកទាហានចូលទៅក្នុងព្រះរាជវាំង ហើយបានប្រហារជីវិតព្រះនាងវ៉ៃ-ជី

ដោយពេញចិត្ត រួចហើយក៏តាំង ជុយ - ស៊ុន ជាបិតារបស់ខ្លួនជាមហា-ក្សត្រគ្រងរាជសម្បត្តិក្រុងចិន កាលពីពុទ្ធសករាជ ១២៧៣ នោះឯង ។

នៅក្នុងវេលានោះ កិច្ចការខាងក្នុងស្រុកកំពុងចលាចលរើកជាខ្លាំង ប្រទេសរាជផ្សេងៗ ក៏នាំគ្នារឹងទទឹងតាំងជាឥស្សរៈឡើង ខ្មាំងសត្រូវខាងក្រៅដែនក៏លើកទ័ពចូលមកមើលស្រុកចិន ឯកំឡាំងទ័ពចិនក៏ទន់ខ្សោយមិនអាចការពារស្រុកទេសបាន ។ ដល់ពេលវេលាហើយដែលក្រុងចិនត្រូវតែកសាងស្រុកទេសឡើងជាថ្មីវិញដូចកាលសម័យ ថៃ - ស៊ុងមហារាជ ព្រះបាទ ជុយ - ស៊ុន ទ្រង់ជ្រាបច្បាស់ថា ព្រះអង្គឯងមិនមែនជាមនុស្សខ្លាំងពូកែទេ លុះទ្រង់គ្រងរាជសម្បត្តិបាន ២ ឆ្នាំ ក៏សុំប្រគល់រាជសម្បត្តិឲ្យទៅរាជឱរស គឺ មិង - កុំង ដែលមានខ្សែលោហិតជាប់មកពីថៃ - ស៊ុងមហារាជជាចំនួនច្រើន ហើយព្រះមហាក្សត្រអង្គនេះឯងដែលទ្រង់ជួសជុលក្រុងចិនឡើងជាថ្មីបាន ។

## អំពីព្រះបាទមិង - កុំងនឹងព្រះនាងយ៉ុង - ហៀ

ព្រះបាទមឹង-កុំងព្រះអង្គមានព្រះនាមមួយទៀតហៅថា ហៀន-ស៊ុង ។ ស្តេចមានព្រះរៀមនឹងព្រះអនុជ ៤ ព្រះអង្គ ក្សត្រ ២ ព្រះអង្គជាព្រះរៀម ២ ព្រះអង្គទៀតជាព្រះអនុជ ។ ព្រះបាទហៀន - ស៊ុង ទ្រង់មានព្រះរាជហឫទ័យស្រឡាញ់ក្សត្រទាំង ៤ ព្រះអង្គណាស់ ដែលទ្រង់បានសោយរាជសម្បត្តិដូច្នេះហើយ ក៏ត្រាស់ហៅព្រះរៀមនឹងព្រះអនុជទាំង ៤ ព្រះអង្គ

ឲ្យទ្រង់មកគង់ នៅជាមួយជានិច្ច ថែមទាំងក្សត្រមួយព្រះអង្គទៀតផង
ដែលត្រូវជាក្មួយជីដូនមួយរបស់ទ្រង់ ។ ឯក្សត្រអង្គនេះត្រូវជាព្រះរាជ-
បុត្រាព្រះបាទពុន - សុន ។ ទ្រង់សោយក្រយាស្ងោយ ក៏សោយជុំ
នៅតុមួយទាំងសងអង្គ ទ្រង់ធ្វើការងារអ្វីក៏ធ្វើជាមួយគ្នា, ព្រះអង្គរាប់
អានក្សត្រទាំង ៥ ព្រះអង្គនេះ ដោយសេចក្ដីមេត្រីស្រឡាញ់ស្និទ្ធស្នាល
អស់ពីព្រះទ័យ ។

មានថ្ងៃមួយនោះ ព្រះអង្គម្ចាស់លី - យ៉ំ ដែលជាព្រះអនុជពៅរបស់
ព្រះអង្គទ្រង់ព្រះប្រឈួន ព្រះរាជាទ្រង់ថែទាំព្រះអនុជដោយព្រះអង្គ
ឯង ។ មានពេលមួយនោះព្រះអង្គស្ដេចទ្រង់ដាំព្រះឧសថព្រះរាជទាន
ព្រះអនុជ ក៏ទ្រង់ឱនទៅជិតភ្លើងៗឆាបឆេះព្រះមស្សុ ពុកមាត់ព្រះអង្គបន្តិច
ទៅ ពួកមហាតលិកឃើញដូច្នោះ ក៏មានសេចក្ដីភិតភ័យតក្កមាជាច្រើន,
តែព្រះបាទហៀន - សុន មានព្រះបន្ទូលត្រាស់ថា "មិនអីទេពុកមាត់
របស់យើង បើឆេះក៏ឆេះទៅចុះ ឲ្យតែព្រះអនុជរបស់យើងបានជា"
ដោយហេតុដែលព្រះអង្គមានព្រះរាជហឫទ័យល្អដូច្នេះហើយ បានជា
ព្រះរៀមនិងព្រះអនុជរបស់ព្រះអង្គ រឹតតែមានសេចក្ដីស្នេហាស្រឡាញ់
ទ្រង់ឡើង ហើយនាំឲ្យក្សត្រទាំងនេះមានព្រះរាជហឫទ័យសុចរិតទៀង
ត្រង់ដល់ព្រះអង្គជាច្រើនថែមទៀតផង ។

តាមដោយពិតនោះ ព្រះបាទមីង - កុំងមានព្រះលក្ខណៈល្អខ្លះ អាក្រក់ខ្លះ តែគួរកប់ថាជាព្រះមហាក្សត្រមានសតិបញ្ញាប៉ុនប្រសប់មួយអង្គបាន ។ អ្នកប្រាជ្ញប្រវត្តិសាស្ត្របារាំងចូលចិត្តនាំយកព្រះបាទមិង-កុំង ទៅប្រៀបធៀបនឹងស្ដេចល្វីទី ១៤ របស់មហាប្រទេសបារាំងសែស ។ ព្រះបាទមិង - កុំងទ្រង់ធ្វើសង្គ្រាមក្នុងរជ្ជសម័យរបស់ព្រះអង្គជាវេលាយូរ ជាន់ដំបូងៗ មានជ័យជំនះ តែតមកក្រោយត្រឡប់ជាបរាជ័យទៅវិញ ចំណែកកិច្ចការខាងក្នុងស្រុកក្រុងនោះ ជាន់ដំបូងមានសេចក្ដីចំរើនល្អណាស់ ទាល់តែអ្នកប្រាជ្ញប្រវត្តិសាស្ត្រពោលថា អ្នកណាមិនបានកើតទាន់រជ្ជព្រះបាទមិង - កុំង អ្នកនោះគង់មិនដែលស្គាល់សេចក្ដីរីករាយក្សេមក្សាន្តក្នុងជីវិតនៅក្រុងចិនដូចម្ដេចទេ ដោយហេតុនេះឯងបានជាអ្នកប្រាជ្ញប្រៀបធៀបព្រះបាទមិង - កុំងនឹងស្ដេចល្វីទី ១៤ នៃក្រុងបារាំងសែស ដែលជាសម័យមានរាជសំណាក់យ៉ាងធំសំបើមអស្ចារ្យ ជាទីសម្រាន្តព្រះរាជហឫទ័យនៃព្រះមហាក្សត្រ តែតមកចុងក្រោយមានការខ្ជះខ្ជាយសប្បាយផ្លូវពេក មានទំនងដូចកាលក្រុងរ៉ូមអស់ឫទ្ធិអំណាច ឬដូចកាលបារាំងសែសកើតបដិវត្តន៍ឡើងដូច្នោះដែរ ។

ក្នុងរជ្ជសម័យនៃព្រះបាទ មិង - កុំង នេះឯងដែលប្រទេសចិនមានកើតអ្នកប្រាជ្ញ នឹងកវីនិពន្ធជាច្រើនប្រដាប់កិត្តិយសរបស់ទ្រង់ជាចំនួនច្រើន ទ្រង់តាំងព្រះអង្គជាអ្នកទំនុកបំរុងកវីនិពន្ធទាំងឡាយទូទៅ ។ ក្នុង

ឆ្នាំពុទ្ធសករាជ ១២៦៦ ទ្រង់តាក់តាំងព្រះរាជបណ្ណាល័យយ៉ាងធំទៀត ហើយតមកក្នុងឆ្នាំពុទ្ធសករាជ ១២៦៨ ទ្រង់តាក់តាំងរាជបណ្ឌិតសភាទៀត ។ ព្រះអង្គឯងក៏ជាអ្នកប្រាជ្ញ, ជាមេភ្លេង, ជាកវី ទើបទ្រង់ជ្រាបដំរៀងនៃវិជ្ជាអស់នេះយ៉ាងច្បាស់លាស់ ។ មានកវីឯក ២ នាក់ ឈ្មោះលី-តៃប៉ោ ១ ឈ្មោះទូ-ហ្វូ ១ ដែលទ្រង់រាប់អានជាមិត្តដ៏ប្រសើររបស់ទ្រង់ ក្រៅអំពីនេះ ព្រះអង្គមានព្រះអគ្គមហេសីជាទីសព្វព្រះរាជហឫទ័យមួយអង្គ ព្រះនាម ព្រះនាងយ៉ុង-ហ្វៃ ជាស្រីដែលយកចិត្តទុកដាក់ជួយទំនុកបំរុងពួកអ្នកប្រាជ្ញរាជបណ្ឌិតៈដោយល្អ ឯខ្លួនព្រះនាងជាគ្រូតន្ត្រីយ៉ាងឯក ទើបឃើញថា រាជសំណាក់ចិនក្នុងសម័យរបស់ព្រះបាទ មិង-ហ៊ុំង ចំរើនរុងរឿងជាបំផុត ។ ក្រុងស៊ីអានក៏ក្លាយទៅជាស្ថានសួគ៌របស់ចិនដូចកវីនិពន្ធ លី-តៃប៉ោនិងទូ-ហ្វូ ពោលពណ៌នាសរសើរសភាពជាទីគួរឲ្យក្សាន្តសប្បាយដ៏ក្រៃលែង ក្នុងសេចក្ដីមួយអទ្វើនោះ ទូ-ហ្វូពោលថា :

"ក្នុងសួនច្បារនៃក្រុងស៊ី-អាននោះ មានវាំងដ៏យមហារាជរបស់ព្រះរាជាធិរាជ ព្រោះតបក់លោសផាយទៅមកជានិច្ច ហើយធម្មជាតិទាំង-ឡាយក៏ល្អស្រស់ផ្សេងៗទៅដោយពណ៌ផ្សេងៗ នៅក្នុងសួនច្បារនេះឯគឺជាទីកើតនៃសេចក្ដីស្នេហារបស់ក្រមុំកំឡោះ ដែលនាំគ្នាទៅតាមស្ងួបតោមពេមជារាជបរិក្រ ។ ស្រីក្រមុំៗ រូបឆោមល្អស្រស់មាន

ចំនួនរាប់មិនអស់ ដែលកាន់ទង់ហ្លួងដើរតាមហែព្រះរាជយាន ក្នុងខណៈដែលស្ដេចចេញទៅប្រពាត ។ នៅក្បែរនោះព្រះអង្គមានរាជនីធ្វើដោយស្លាបក្ងោកបោកបក់ថ្វាយជានិច្ច នាំឲ្យមើលឃើញលំអដ៏រុងរឿង ព្រះស្នៀងជាព្រះរាជយានសោតទៀត ក៏មានមណ្ឌបតូចមួយបិទបាំងដោយព្រះសន្ធិយាដែលប្រដាប់តាក់តែងដោយត្បូងខៀវមុក្ខ ធំងប៉ុកជារូបសត្វដែលគេបានដោយកម្រណាស់ ។ កាលបើស្ដេចចេញទៅប្រពាតតាមជើងទឹក ស្ដេចតែងទ្រង់គង់នាវព្រះទីនាំងដែលមានសសរក្ដោងធ្វើដោយភ្លុកដំរី ហើយសន្ទូកក្ដោងធ្វើដោយសំពត់ព្រែសូត្រយ៉ាងល្អ កាលប្រែកបង្វែរទៅទីណាទឹកដ៏ថ្លាស្អាតគួរទស្សនាហើយ ទ្រង់ត្រាយនាវព្រះទីនាំងមានសណ្ឋានដូចសត្វស្វាន យ៉ាងល្អវិសេសមួយហែបហែលគង់ព័រ ១ ។

ព្រះនាងយ៉ុង-ហ្វៃមិនមែនត្រឹមតែជាស្ត្រីមានរូបឆោមល្អប៉ុណ្ណោះទេ ព្រះនាងនៅមានចំណេះចេះដឹង នឹងសេចក្ដីឆ្លៀវឆ្លាតជាគ្រឿងប្រដាប់ដោយឡែកថែមទៀតផង ។ អ្នកប្រាជ្ញប្រវត្តិសាស្ត្រចូលចិត្តប្រៀបធៀបព្រះនាងយ៉ុង-ហ្វៃនឹងម៉ាដាម ប៉ុមប៉ាឌួរបស់បារាំងសែស ព្រោះហេតុព្រះនាងយ៉ុង-ហ្វៃគាប់គាន់បេះដូងរបស់ព្រះបាទមិង-ហ៊ាំងមុតទុកក្នុងដៃបាន មានទំនងដូចម៉ាដាមប៉ុមប៉ាឌួគាប់បេះដូងព្រះបាទល្វីទី ១៥ ទុកក្នុងដៃបានដូច្នោះដែរ ។ ប្រសិនបើព្រះបាទមិង-ហ៊ាំងស្ដេចគង់ក្នុងក្រុង

ស៊ី-អ៉ានហើយ ទ្រង់មិនដែលឃ្លាតឆ្ងាយពីព្រះនាងយ៉ុង-ហ្វៃឡើយ ។ ក្នុងវេលាគ្រាមួយនោះ ជាវេលាគ្រៃថ្ងៃមេឃស្រឡះភ្លឺត្រចះត្រចង់ដោយពន្លឺព្រះចន្ទ្រា ព្រះបាទមិង-ហ្វាំងស្ដេចប្រថាប់ជាមួយនឹងព្រះនាងយ៉ុងហ្វៃ ហាក់ដូចជាទ្រង់សប្បាយរីករាយក្នុងព្រះរាជហឫទ័យណាស់ ទើបមានព្រះបន្ទូលឲ្យហៅខុនលី-តៃប៉ោទៅគាល់ ហើយទ្រង់ប្រទានក្រដាសឲ្យលី-តៃប៉ោ ៣ សន្លឹក ។ លី-តៃប៉ោក៏តែងជាកាព្យ ៣ បទថ្វាយក្នុងវេលានោះ ឯកាព្យឃ្លោងទាំង ៣ បទនោះគេនិយមរាប់អានជាយ៉ាងឯកក្នុងពួកអក្សរសាស្ត្រចិនរហូតមកដល់សព្វថ្ងៃនេះ ។

« ទ្រង់ទតពពកអណ្ដែតលើនភា
ព្រះរាជាទ្រង់មានព្រះបំណង
ហាក់ដូចព្រះនាងយាងមកសាសង
ខ្លួនល្អងបែរកាយនែបអែបព្រះអង្គ ។
ស្ដេចទ្រង់ទតសួនបុប្ផាផ្កានានា
ព្រះទ័យរីករាយថ្លាត្រយង
ហាក់ដូចបានយល់ភក្ត្រាល្អបញ្ចង់
រូបកាយស្រស់ធ្លូរផង់មានរស្មី ។

ក្នុងរាត្រីនេះរុងរឿងជាបំផុត
បមមកុដ៏ទេពបន្រ្ទឆាយល្អពីសី
ផ្កាផងផ្សាយក្លិនក្រអូបហឺយបក្រិ
ទាំងស្រស់ស្រីគង់ផ្ទឹមទន្ទឹមអើយ " ។

កាព្យឃ្លោងទាំង ៣ បទរបស់លី-តៃប៉ោ នេះ ជាសេចក្តីពីរោះ ចាប់ចិត្តរបស់ចិន្តកវីចិន សមជាទីប្រោសប្រាណរបស់ព្រះបាទយ៉ិន-កុង និងព្រះនាងយ៉ុង-ហ្វៃ ពិតមែន ។ តែបើថាជាមិនពីរោះចាប់ចិត្តរបស់អ្នកអានប្រតិសាស្ត្រនេះ កុំបីបន្ទោសដល់ទៅលី-តៃប៉ោឡើយ សូមឲ្យបន្ទោសតែត្រឹមរូបអ្នកប្រែនេះបានហើយ ព្រោះមិនសូវប៉ិនប្រសប់ខាងរបៀបតែងកាព្យឃ្លោង ។

## ទំពប៊ិនឈ្មោះមេប៊ូអ៊ូ

---

ការចលាចលវឹកវរបានកើតឡើងតាំងពីចុងរាជ្យព្រះបាទ តៅ-សុង នោះ តែត្រឡប់ជាស្ងប់រៀបរយទៅវិញបាន ។ ការត្រង់ណោះ គួរសារសើរព្រះនាង វូ-ហៅ គឺក្នុងឆ្នាំពុទ្ធសករាជ ១២៣៥ នោះ ព្រះរាជិនីមានចិត្តប៉ឺងរឹងរុះព្រះអង្គនេះ បានចាត់បញ្ជូនកងទ័ពចិនទៅដណ្តើមយកដែនដីផ្សេងៗ ខាងកប-គារួមទាំងស្រុកកុលជា និងខាងការាម៉ាពី ពួកទីបេត៍បានមកទៀត (មានត)

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម ប្រែ រៀបរៀង

(តមក)

---

| | | | |
|---|---|---|---|
| ១. ទ្វីបអាស៊ី | មានទំហំដី | ៤៥.០០០.០០០ | គីឡូម៉ែត្រក្រឡា |
| ២. ទ្វីបអាហ្វ្រិក | " | ៣០.០០០.០០០ | " |
| ៣. ទ្វីបអាមេរិចខាងជើង | " | ២២ ០០០.០០០ | " |
| ៤. ទ្វីបអាមេរិចខាងត្បូង | " | ១៨.៦០០.០០០ | " |
| ៥. ទ្វីបអឺរ៉ុប | " | ១០.០០០.០០០ | " |
| ៦. ទ្វីបអូស្ត្រាលី | " | ៧ ៧៧០.០០០ | " |
| ៧. ទ្វីបអង់តាក់ទិក | " | ១២.៤៥០.០០០ | " |
| ឯទីឯទៀតៗ | " | ៦៨០.០០០ | " |

១៤.— ផ្ទៃដីនៃទ្វីបផ្សេងៗ.— បណ្ដាទ្វីបអស់នេះ ទ្វីបណាមានទីដីទួល, ដីរាប, ដីខ្ពស់, ដីទំនាប ត្រឹមណានោះ ចំពោះទ្វីបអឺរ៉ុបមានដីរាបធំច្រើនជាងពាក់កណ្ដាលរបស់ទីដីនៃទ្វីបទាំងមូល ឯទីដីរាបធំរបស់ទ្វីបអឺរ៉ុបនៅកណ្ដាលទ្វីប រាប់តាំងអំពីទិសខាងជើងប្រទេសបារាំងសែស និងប្រទេសអាល្លឺម៉ាញរហូតទៅទល់នឹងភ្នំអ៊ូរ៉ាល់ ដែលជាទីបែងចែកព្រំប្រទល់ដែនទ្វីបអឺរ៉ុបនិងទ្វីបអាស៊ី ហើយដីរាបធំនេះជាទីដីមានជីជាតិល្អ ប្រកបទាំងមានធាតុដែកនិងធ្យូងថ្មជាចំនួនច្រើនផង ហើយប្រ-

ជាផ្នែកដែលអាស្រ័យនៅនាទីដំបន់មូសុងនេះ មានចំនួនច្រើនណែនណាន់ កាន់កាប់មួយនៅក្នុងលោកនេះ ។

ទ្វីបដែលមានទីដីខ្ពស់ (ជាង ១.៨០០ ម៉ែត្រ) ដោយភាគច្រើននៅទ្វីបអាស៊ីចំណែកទីដីខ្ពស់នេះ គឺតាំងពីអាស៊ីមីនឿលោតចេញទៅទិសខាងកើត កាត់ប្រទេសអ៊ីរ៉ង់, អាស៊ីកណ្ដាល, បរិវេណភ្នំហិម៉ាល័យ ហើយហួសទៅដល់ចុងដែនប្រទេសទីបេ ដែលជាប្រទេសតាំងនៅលើទីខ្ពស់បំផុតក្នុងលោក (៣.៦០០–៤.៥២០ ម៉ែត្រ) ផ្ទៃដែនដីនៃទ្វីបអាស៊ីពាទ្វាល ឬជាទីកខ្ពស់មានចំនួនច្រើនជាងពាក់កណ្ដាលនៃគ្រប់ទ្វីបទាំងមូល ទីដីទំនាបមានតិច ព្រោះហេតុដីកប់ធំនៅភាគខាងជើងនៃទ្វីបនេះជាទីខ្ពស់ ច្រើនតែខ្ពស់ជាង ១៨០០ ម៉ែត្រ ដីកបខាងជើងទីដីទួលនៅកណ្ដាលទ្វីបទាំង ២ អន្លើនេះមានចំនួនមនុស្សស្តើងៗ ឯចំនួនមនុស្សច្រើនតែគុះគរនៅតាមទីដីទំនាប គឺដីទំនាបតាមដងទន្លេគង្គាក្នុងប្រទេសឥណ្ឌា និងដីទំនាបតាមដងទន្លេធំៗនៅចំណែកប្រទេសចិនទិសខាងកើត ប្រសិនបើរួមប្រជាជនទាំង.២ ប្រទេសនេះរួមគ្នា និងមានចំនួនដល់ទៅ ៧០០ លាននាក់ គឺត្រូវជា ៣ ភាគក្នុង ៤ ភាគនៃប្រជាជនក្នុងទ្វីបទាំងមូល ។

បើគិតប្រៀបធៀបគ្នានឹងឃើញថា ទ្វីបអាហ្វ្រិកមានដីទួលច្រើនជាងទ្វីបឯទៀតៗ ។ ដីទួលមានប្រមាណ ៤ ក្នុង ៥ ភាគនៃគ្រប់ទ្វីបទាំងមូល

ឯទីទំនាបក្នុងបស្ចឹមមានចំនួនតិច ៗ ឯទ្វីបអូស្ត្រាលីក៏មានជំរាលច្រើនជាងពាក់កណ្តាលផែ ឯទ្វីបអាមេរិកខាងជើងនិងខាងត្បូងមានជំខ្ពស់ប្រហែលៗគ្នា តែទ្វីបអាមេរិកខាងជើងមានទីជទំនាបតិចជាង ព្រោះដីកបផ្ទាំងធំនៃទ្វីបអាមេរិកខាងជើងរាងកណ្តាលនៃអាមេរិក មានកំពស់ជាង ១៨០ ម៉ែត្រ ឡើងទៅស្ទើរតែទាំងអស់ ៗ

១៥ – អំពីមហាសមុទ្រ – បានពោលហើយថា លើផ្ទៃពិភពលោកយើងនេះ មានចំនួនទឹកដល់ទៅ ៣៦៣.០០០.០០០ គីឡូម៉ែត្រក្រឡា អ្នកប្រាជ្ញភូមិសាស្ត្របានចែកទឹកដ៏ធំសំបើមនេះចេញជា ៥ ភាគគឺ:

| ឈ្មោះមហាសមុទ្រ | គិតជាគីឡូម៉ែត្រក្រឡា | ជំរៅគិតជាម៉ែត្រ |
|---|---|---|
| ១. ប៉ាស៊ីហ្វិក | ១៦៧.០០០.០០០ | ៩៤៥០ |
| ២. អាត្លង់ទិក | ៩០.៦០០.០០០ | ៩៤១០ |
| ៣. ឥណ្ឌា | ៦៤.៧០០.០០០ | ៦៨៨៩ |
| ៤. អាកទិក | ១៤.០០០.០០០ | ៣៩២០ |
| ៥. អង់តាក់ទិក | ១១.០០០.០០០ | — |

១៦ – អំពីទឹកសមុទ្រ – ហេតុដែលទឹកសមុទ្រមានរសជាតិប្រៃ ដោយមកអំពីជាតិអំបិលចំពួកផ្សេងៗ ឯសមុទ្រណាដែលមានទឹកក្លាយទៅជាចំហាយមានចំនួនតិច ហើយបានទទួលទឹកសាបដែលហៀរហូរ

ហូរមកអំពីជ្រោះជ្រលង ស្ទឹងទន្លេជាចំនួនច្រើន សមុទ្រនោះមានជាតិអំបិលតិច ទើបធ្វើឲ្យទឹកសមុទ្រនេះមានរសជាតិមិនសូវប្រៃ ។ ឯសមុទ្រណាដែលមានផ្លូវទឹកសាបហូរចូលតិច ហើយត្រូវកំដៅថ្ងៃខ្លាំងទឹកសមុទ្រក៏ក្លាយទៅជាចំហាយច្រើន សមុទ្រនេះមានជាតិអំបិលច្រើនដូចជាសមុទ្រក្នុងប្រទេសប៉ាលេស្ទីន មានរសជាតិប្រៃបំផុតក្នុងលោកដោយហេតុមិនបានទទួលទឹកសាបពីផ្លូវទឹកតាមដងទន្លេណាមួយឡើយ ។

១៧.— អំពីហេតុរំជួលនៃមហាសមុទ្រ- ហេតុរំជួលនៃមហាសមុទ្រនេះមាន ៣ ប្រការគឺ ១.រលក ២.ខ្សែទឹក ៣.ទឹកឡើងទឹកចុះ (ជោរនាច) ។

រលក កើតឡើងដោយខ្យល់ដែលបក់ផាត់ទឹកឲ្យរញ្ជួយរលកតូចឬធំស្រេចហើយតែកំឡាំងរបស់ខ្យល់ ។

ខ្សែទឹក ហេតុដែលកើតខ្សែទឹក ដោយហេតុផ្ទៃទឹកក្នុងភាគក្តៅនៃពិភពលោកបានទទួលកំដៅថ្ងៃខ្លាំងក្លាជាងផ្ទៃទឹកក្នុងភាគឯទៀត ។ ដូចជានៅភាគនៅត្រជាក់ជាដើម កាលបើទឹកក្តៅក៏មានអាការប៉ោងខ្ពង់ឡើង ទើបធ្វើឲ្យផ្ទៃទឹកចំណែកនេះខ្ពស់ឡើងជាងទឹកក្នុងភាគនៅដែលជាទឹកត្រជាក់ហើយមានសភាពណែនជាងទឹកក្តៅ ទើបធ្វើឲ្យទឹកក្នុងភាគក្តៅហៀរហូរលិចទៅលើផ្ទៃទឹកតាមប៉ូលលោកទាំងពីរដែលមានកំពស់ទឹកទាបជាង ទើបធ្វើឲ្យកើតខ្សែទឹកលើទឹកឡើង ។ ឯទឹកសមុទ្រក្នុងភាគត្រ-

ដាក់រនាំដែលមានទម្ងន់ណែនកាន់ច្រើន នោះជាហេតុធ្វើឲ្យទឹកនេះហូរជ្រែកចូលទៅក្នុងទឹកខាងភាគក្តៅដែលស្រាលជាង ទើបជាហេតុឲ្យកើតខ្សែទឹកខាងក្រោមទឹកឡើង តែដំណើររបស់ខ្សែទឹកនោះ មិនហូរត្រង់ទៅទិសខាងជើងនិងខាងត្បូងត្រង់ៗ តាមដែលយើងយល់ដូច្នេះទេ ព្រោះមានហេតុផ្សេងទៀត ជាគ្រឿងប្រកបទើបជាហេតុឲ្យខ្សែទឹកផ្លាស់ផ្លូវដើរចំពៃ ៗ ពីគ្នា គឺ:

១.— ផ្លូវខ្យល់ប្រចាំ អ្នកប្រាជ្ញភូមិសាស្ត្រជាច្រើននាក់ពោលថា ខ្យល់ប្រចាំផ្លូវ ជាហេតុយ៉ាងសំខាន់ដែលធ្វើឲ្យខ្សែទឹកហូរទៅតាមផ្លូវណា ណាមួយបាន ក្នុងភាគដែលមានខ្យល់បក់ទៅទិសខាងលិចឆៀងខាងជើង ឬទិសខាងលិចឆៀងខាងត្បូង រមែងមានរហូត ១ ឆ្នាំពេញ យើងនឹងមើលឃើញខ្សែទឹកដែលហូរចេញពីភាគក្តៅ សំដៅទៅទិសខាងលិចតែមួយផ្លូវ ដូចខ្សែទឹកនៅខ្សែស្មូស្យខាងជើងនិងខ្សែស្មូស្យខាងត្បូងជាដើម ៗ នៅតំបន់ដែលមានខ្យល់ប្រចាំបក់ទៅទិសខាងកើតតែមួយផ្លូវ ដូចខ្សែទឹកអង់តាទិកនិងខ្សែទឹកកុរោស៊ីវោជាដើម ៗ

២– ការវិលជុំវិញខ្លួនឯងនៃពិភពលោក — ការវិលជុំវិញខ្លួនឯងនៃពិភពលោកនេះរមែងធ្វើឲ្យវត្ថុផ្សេងៗ មានអាការរញ្ជួយទៅតាមផ្ទៃពិភពដូចខ្យល់និងខ្សែទឹកជាដើមផ្លាស់ប្រែផ្លូវទៅបាន នៅភាគខាងជើង

ខ្សែស្បូវទឹងបែរផ្លូវទៅខាងស្តាំ ហើយការខាងត្បូងស្បូវទឹងបែរទៅខាងឆ្វេង ៗ

៣ — អំពីទីតាំងផែនដី — ប្រសិនបើមិនមានផែនដីតាំងទៅតាមបរិវេណខ្សែស្បូវទេ ខ្សែទឹកក៏នឹងហូរទៅជុំវិញលោកសំដៅទៅទិសខាងលិចរហូតទៅ ប៉ុន្តែពេលបើមានផែនដីមកទទឹងមុខទឹក ផ្លូវដើររបស់មុខទឹក ក៏ត្រូវតែបែរបៀសបែរទៅតាមទិសខាងជើងខ្លះទៅទិសខាងត្បូងខ្លះ ហើយជាដើមហេតុធ្វើឲ្យទឹកក្តៅ ដែលហូរចេញពីកាតក្តៅរបស់លោក ហៀរហូរហួសទៅកាន់ទីដែលត្រជាក់ជាង ឯនៅចំណែកទឹកខ្លះដែលហូរទៅប៉ះផ្ទាំងទឹងពីមុខនេះបែរជាហូរវិលត្រឡប់មកទិសខាងដើមវិញទៀតក៏មានៗ

## — ១៨ អំណាចរបស់ខ្សែទឹកដែលទាក់ទាមនឹងអាកាស

ទឹកឧណ្ហក្តៅដែលចេញពីកាតក្តៅជួយធ្វើឲ្យឧណ្ហភូមិនៅបែតខាងកំពូល (ប៉ូល) លោកស្ទុះខ្ពស់ឡើង ឯទឹកត្រជាក់ចេញអំពីតំបន់នោះជួយបន្ថយឧណ្ហភូមិក្នុងតំបន់ផ្សេងៗ នៅចំណែកខ្សែស្បូវ ៗ ដែលពោលមកនេះ មានគំនិតគាត់មើលឃើញច្បាស់ នៅចំណែកខាងមហាសមុទ្រអត្លង់ទិចខាងជើងនោះ មានខ្សែទឹកទឹងខ្យល់ទិសខាងកើតធៀនខាងត្បូងខាងដំណើរទៅជាមួយគ្នា ជួយធ្វើឲ្យកំពង់កប៉ាល់ប្រទេសណរវែសឥតទឹកកករហូតពេញ ១ ឆ្នាំ ៗ ឯកំពង់កប៉ាល់ក្នុងសមុទ្រដែលនៅក្រោមប្រទេសណរវែសចុះមកដល់ ៩០០ គីឡូម៉ែត្រឡើងទៅ ដូចជានៅក្នុងសមុទ្រ

បាល់ទិក និងសមុទ្រខ្មៅជាដើម ត្រឡប់ជាមានទឹកកកណែនក្តាំងក្នុងផ្ទៃរលោជាហេតុធ្វើឲ្យកប៉ាល់ជំនួញនានាដើរតាមកំពង់អស់នេះ គាំងឈប់ផ្អាកជាច្រើនខែ ។ ខាងជើងអាមេរិកក៏មានតំរូវបែបនេះដែរ គឺខ្សែទឹកត្រជាក់ភាគទិសហូរចុះមកខាងក្រោម ( ខាងត្បូង ) ទឹកហូរកាត់ច្រាំងសមុទ្រទិសខាងកើតរបស់ប្រទេសកាណាដា និងសហរដ្ឋអាមេរិក ធ្វើឲ្យច្រាំងសមុទ្រខ្សែព្រំដែនរបស់ប្រទេសកាណាដា ដែលតាំងនៅក្នុងខ្នង់ខ្សែជាមួយនឹងប្រទេសអង់គ្លេស ត្រឡប់ជាមានទឹកកកតាប់នៅបានយូរដល់ ៩ ខែ ហើយធ្វើឲ្យស្រុកណែវយ៉កដែលតាំងនៅក្នុងខ្នង់ខ្សែលើស ៤០ អង្សា មានអាកាសត្រជាក់ខ្លាំងក្នុងផ្ទៃរលោប្រហែលនឹងភាគខាងជើងផុតនៃប្រទេសណរ៉វែសដែលតាំងនៅខ្សែខ្នង់លើដល់ ៧១ អង្សា ។

ខ្សែទឹកតែងប្រគល់ចំណ្ហក្តុំឲ្យខ្យល់ហើយខ្យល់បក់យកកំដៅ ឬត្រជាក់ទៅប្រគល់ឲ្យផែនដីមួយជាន់ទៀត ។

១៩ — អំពីខ្សែទឹកក្នុងសមុទ្រ — ខ្សែទឹកក្នុងសមុទ្រនោះ មិនទាក់ទិននឹងខ្សែទឹកក្នុងមហាសមុទ្រទេ ឯខ្សែទឹកក្នុងសមុទ្រកើតពីហេតុសំខាន់២ ប្រការ គឺទឹកសមុទ្រត្រូវកំដៅថ្ងៃដុតឲ្យក្លាយជាចំហាយឡើងទៅប្រការ ១ ហេតុដែលទន្លេព្រែកដែលនិងស្ទឹងបង្ហូរទឹកសាបមកចូលសមុទ្រប្រការ ១ តែប្រសិនបើបរិមាណទឹកសាបមានចំនួនច្រើនជាងបរិមាណទឹកសមុទ្រដែលក្លាយជាចំហាយទៅ នឹងកើតទៅជាខ្សែ

ទឹកហូរចូលទៅមហាសមុទ្រ ដូចយ៉ាងក្នុងសមុទ្រខ្មៅ, សមុទ្របាល់ទិក, ឈូងសមុទ្រហ័រស្សនទីងឈូងសមុទ្រសៀមជាដើម ។ ប្រសិនបើចំនួនទឹកសមុទ្រដែលក្លាយជាចំហាយទៅច្រើនជាងទឹកដែលហូរមកពីផ្លូវទឹកផ្សេងៗ ក៏នឹងកើតជាខ្សែទឹកមហាសមុទ្រហូរចូលមកក្នុងសមុទ្រនោះៗវិញ ដូចជាខ្សែទឹកក្នុងសមុទ្រមេឌីទេរ៉ាណេនិងសមុទ្រក្រហមជាដើម ។

២០- **អំពីទឹកជោរនាច**.— នៅតាមឆ្នេរសមុទ្រនឹងទន្លេខ្លះត្រង់ស្ទឹងចិនប្លែងទៅជិតសមុទ្រ តែងមានទឹកចុះ ១ ឡើង ១ ជានិច្ចដែលហៅថាទឹកជោរនាច គឺកាលបើទឹកចុះទាបដល់ទីបំផុតហើយក៏ជោរជន់ឡើងវិញជាវេលាប្រមាណ ៦ ម៉ោង ១៣ នាទី តអំពីនេះទៅទឹកក៏នាចហូរចុះទៅវិញដូចដើម ជាវេលា ៦ ម៉ោង ១៣ នាទីដែរ តែងតែដូច្នេះក្នុង ១ ថ្ងៃ ក្នុងវេលា ២៤ ម៉ោង ៥១ នាទី នឹងមានទឹកឡើង ២ ដងទឹកនាច ២ ដងជាដរាប ។

ហេតុដែលមានទឹកឡើងចុះនេះ កើតមកអំពីអំណាចរបស់ដួងច័ន្ទ។ យើងដឹងច្បាស់ហើយថា វត្ថុផ្សេង ១ រមែងមានអាការស្រូបទាញយឹតយោងគ្នាទៅវិញទៅមក មានទំនងដូចជាលោកនឹងដួងច័ន្ទដួងអាទិត្យក៏មានអាការស្រូបទាញយឹតយោងគ្នា អំណាចយឹតយោងនៃដួងច័ន្ទនឹងដួងអាទិត្យនេះហើយ ជាបច្ច័យយ៉ាងសំខាន់ក្នុងការធ្វើឲ្យមានទឹកជោរនាចនៅលោកយើងនេះ ។ កាលណាផ្នែកពិភពលោកងាកទៅចំដួងច័ន្ទ

កាលនេះទើបមានទឹកជោរជន់ឡើងប្រែនជាងកាលដទៃទៀត ឯភាគផែនដីមួយចំហៀងទៀត ដែលនៅចំទិសភាគដែលនៅជិតដួងចន្ទ្រក៏មានទឹកជោរជន់ឡើងដែរ តែ ២ ភាគទៀតនោះទើបមានទឹកស្រកទៅវិញ ។

តាមធម្មតា ការវិលនៃដួងពិភពនេះ ធ្វើឲ្យទឹកសមុទ្រគ្រប់ៗតំបន់ជោរនាច ២ ដងក្នុង ១ ថ្ងៃ គឺ ជោរ ២ ដង នាច ២ ដង លុះក្នុងថ្ងៃក្រោយមកទឹកជោរនាចនឹងយឺតជាងថ្ងៃដំបូងៗ ប្រមាណ ៥១ នាទី ដូចជាថ្ងៃនេះទឹកជោរឡើងវេលាម៉ោង ១២ ថ្ងៃត្រង់ លុះដល់ថ្ងៃស្អែក ទឹកឡើងក្នុងវេលាម៉ោង ១២ និង ៥១ នាទី ដោយអំណាចការនាចរបស់ដួងចន្ទ្រ ឃ្លាតចេញពីដំណែងដើមបន្តិចៗ ទៅជានិច្ចរាល់ថ្ងៃ ទើបធ្វើឲ្យទឹកជោរនាចមានដំណើរយឺតជាងថ្ងៃមុនៗ ប្រមាណ ៥១ នាទីរាល់ថ្ងៃ ។

ឯដួងអាទិត្យក៏មានចំណែកជួយធ្វើឲ្យកើតទឹកជោរនាច បានខ្លះដែរ តែកំឡាំងដួងអាទិត្យដែលយឺតយោងលោកមានកំឡាំងខ្សោយជាងដួងចន្ទ្រប្រែន ប្រមាណ ២ ក្នុង ៥ ភាគ ព្រោះដួងអាទិត្យនៅឃ្លាតឆ្ងាយពីលោកយើងជាងដួងចន្ទ្រដល់ ៤០០ ភាគ ។

អំពីទឹកប្រឹងតិប — កាលណាដួងអាទិត្យដួងចន្ទ្រក្នុងពីរយៈខ្ទង់ជាមួយគ្នានឹងលោក ទើបដួងអាទិត្យនិងដួងចន្ទ្ររួមកំឡាំងគ្នាជាពីរស្រូបយកលោកនេះ ទើបធ្វើឲ្យទឹកជោរជន់ឡើងប្រែនខុសប្រក្រតី (ត្រូវនឹងថ្ងៃ ១៤-១៥ កើត ឬ ១៥ កើតឬក្រោយនេះ ១ ថ្ងៃ ២ ថ្ងៃ) ទឹកប្រែននេះមាន

ក្នុង១ខែ២ដង មានរយៈឃ្លាតពីគ្នា១៥ថ្ងៃ តែថាបើព្រះអាទិត្យនៅជាកាត់ត្រង់ផែនដីនិងព្រះចន្ទ ដូចជាក្នុងពេល ៧-៨ ខាងកើតឬខាងរនោច កំឡាំងយឺតយោនរបស់ព្រះចន្ទនិងព្រះអាទិត្យទៅជាប្រឆាំងគ្នា មិនស្របគ្នាទេ ទើបធ្វើឲ្យទឹកឡើងតែបន្តិចបន្តួចប៉ុណ្ណោះ ទឹកតិចនេះក្នុង១ខែមាន២ដងដែរ ។

ឯកំឡាំងយឺតយោនរបស់ព្រះចន្ទដែលមានមកលើផ្ទៃពិភពនេះ ប្រហែល ៥ ភាគ កំឡាំងព្រះអាទិត្យ ២ ភាគ កាលដែលមានទឹកជោរជន់ឡើងច្រើន ព្រះចន្ទនិងព្រះអាទិត្យរួមកំឡាំងគ្នាយឺតយោនទឹកឡើងទើបត្រូវជាកំឡាំងយឺតយោន: ៥ + ២ គឺ ៧ វេលាដែលមានទឹកឡើងតិច កំឡាំងយឺតយោនទើបត្រូវជា: ៥ — ២ គឺ ៣ កំរិតទឹកក្នុងថ្ងៃទឹកច្រើន ប្រៀបនឹងថ្ងៃទឹកតិច ទើបត្រូវជា: ៧ - ២ ។

## វគ្គទី ៣ និយាយពីខ្យល់អាកាស

**២១ — បរិយាកាស. —** គឺអាកាសដែលហ៊ុំព័ទ្ធជុំវិញលោក អាកាសនេះមានធាតុចំហាយផ្សេងៗ បើប្រមូលទៅប្រមាណ ១០០ ភាគ នឹងមានធាតុចំហាយមានប្រមាណដូច្នេះ គឺនីត្រូសែន ៧៧,១២ អុកស៊ីសែន ២០,៦៦ ចំហាយទឹក ១,៤ អាគុង ០,៧៩ អុកស៊ីតកាបូន ០,០៣, និងធាតុចំហាយហ៊ីត្រូសែន គ្រិបតុង នេអុង និងហេល្យ៉ូម ម្យ៉ាងបន្តិចៗទៀត ។ ក្នុងបរិវេណជិតៗផ្ទៃលោកជាយជុំវិញនេះ (មានត)

ឯកសហាស្រកក្រៃ

ភាគទី ១៩

# ឃុនសុន្ទរមេធី ញ៉ង-សឿង ប្រែ

## លោក ហង់-គិមសេង ពិនិត្យ

(តមក)

---

គ្រាដែលបានឃើញបេទ្រេទឌិនហាស្យ៉ុនចូលទៅដល់ភ្លាម ស្ត្រីទាំងឡាយក៏ផ្អើលឈ្ងោករកោមមើលគ្រប់គ្នា ហើយសើចសរសើរកល់មាត់អំពីលក្ខណៈសក្តិសមគតខ្លោះរបស់គេទ្បោះនោះ; កាលបេទ្រេទឌិនហាស្យ៉ុនអង្គុយហើយ ឥតមានស្ត្រីណាមួយអង្គុយស្ងៀមត្រង់កន្លែងខ្លួនបានទេ នាំគ្នាក្រោកឈរខិតចូលទៅជិតពិនិត្យមើលឲ្យច្បាស់លាស់ៗ ដល់វេលាថយទៅកាន់កន្លែងរបស់ខ្លួនវិញ ស្រីទាំងឡាយនោះមានសេចក្តីរន្ធត់ត្រីត្រួបចិត្តគ្រប់ៗគ្នា ។

បេទ្រេទឌិន ហាស្យ៉ុន នឹងបុរសគម ខុសប្លែកពីគ្នាឆ្ងាយណាស់ ព្រោះបុរសគមនោះមានរូបអាក្រក់ ក្រៃណា នឹងអាក្រក់ មើលទៅគួរឲ្យខ្ពើមរអើម នាំបណ្តាលឲ្យបណ្តាជនក្នុងទីសន្និបាតនោះខ្សឹបខ្សៀវគ្នាឮៗ ពួកស្រីៗអស់ទាំងមិនបាននាំគ្នានិយាយតគ្នាឡើងថា "ត្រូវតែឲ្យកូនក្រមុំយើងមកអួតគេទ្បោះរូបស្រស់នេះវិញទើបសម, មិនត្រូវឲ្យទៅបុរសគម

តំរង់នោះទេ" ។ ស្រីទាំងឡាយមិននៅស្ងៀមស្ងាត់តែប៉ុណ្ណោះឡើយ ហ៊ានដល់ទៅកោសរួសបន្ទោសដៀលត្មះដល់ស្តេចទៀតផងថាមិនសមបើ ដាក់អាជ្ញាបង្ខិតបង្ខំឲ្យយកមនុស្សស្រុកអតពមន្ត្រីលមកប្រមូលជាមួយនឹងស្រី ជាមន្ត្រីគ្រប់លក្ខណ៍ប្រូបេះបោះ ។ មិនតែប៉ុណ្ណោះសោតស្រីទាំងនោះ នាំគ្នាបន្ទះបញ្ជាប់ដេរប្រែទេចផ្កាសាត់ណាគកំហែងប្រុសតមឲ្យស្ងួតកាន់កាំងស្នាតើ, ស្រូសព្ទមាត់លាន់ឡើងហ៊ឹងអឺងកង់ឡប់សព្ទសាយពេញទាំងផ្ទះ ទាល់តែកូនដែលគេតួរលេងកង្ហើទោះ ឈប់បន្តអស់មួយស្របក់; លះស្ងប់មាត់គរវៃគរពោកហើយ ទើបពួកអ្នកក្រុងហាប់លេងតទៅទៀត, ចំណែកស្រីៗ ដែលចំរើនទឹងសិតអិតសំអាងតែខ្លួនឲ្យក្រូចក្រមុំកំដរតួលទៅជិតនាត់ ។

គ្រប់ ១ ខណៈដែលផ្កាសព្វសំលៀកបំពាក់, ដីតានោះក្រោកពីកន្ទេលខ្លួន មានទាំងពួកស្រីដាប់កាហែហមអមទៅផង ដើរកាត់មុខប្រុសតម ដោយឥតគិតពិចារណាមើលបន្តិចសោះ ហួសទៅឈរខាងមុខរបេទេទឹង ហស្សែន ដើម្បីបង្ហាញឲ្យគេមើលគ្រឿងតែងខ្លួនថ្មីៗ ។ ខណៈនោះ បេទេទឹង ហស្សែន ធ្វើតាមទំលាប់ដែលបិសាចបានតម្រាល់ហើយ ទើបលូកយកប្រាក់ពីក្នុងថង់ពេញៗដៃ ហុចចែកឲ្យស្រីៗ ដែលហែហមអមកំដរក្មួស្រកថ្មីព្រមទាំងបិសាចឲ្យពួកអ្នកភ្លេងទាំងពួក ប៉ោងទាំង មើលទៅគួរឲ្យស្របព្វាយរីកពោយណាស់ អ្នកទាំងអស់នោះដណ្ដើម

រើសប្រាក់ដែលប្រថល់ពពាក់ពពូនប្រជៀតរុញច្រានគ្នាទៅវិញទៅមក, បានសំដែងសេចក្ដីដឹងគុណជាអនេកហើយឲ្យសញ្ញាថា, គេទាំងអស់គ្នាពេញចិត្តឲ្យមានក្រមុំមកបម្រើបេទ្រឌិន ហស្សនវិញ, មិនត្រូវឲ្យទៅបុរសគមនេះទេ; ពួកស្រីៗដែលកំដរស្រីក៏បានជាឆ្លើយស្រុះស្របគ្នាដូច្នោះដែរ ហើយឥតរវល់អើពើនឹងបុរសគមនោះ ។

កាលបើពិធីផ្លាស់ប្ដូរសំលៀកបំពាក់ជាច្រើនលើកនោះរួចរាល់សព្វគ្រប់ហើយ ពួកអ្នកភ្លេងក៏ឈប់លេងហើយបានឲ្យសញ្ញាដល់បេទ្រឌិន ហស្សនថាឲ្យនៅក្នុងបន្ទប់នោះចុះ រួចគេនាំគ្នាថយចេញអស់ទៅ ។ បន្ទាប់មក ស្រីទាំងឡាយបានឲ្យសញ្ញាដូចគ្នាហើយចេញទៅដែរ, បំណែកខាងភរិយាជាសាម៉ីខ្លួនចូលទៅក្នុងបន្ទប់គួបសម្រាប់ផ្ទំដំណេក មានស្រីៗជាបរិវារចូលតាមទៅជាមួយផង ដើម្បីជួយដោះសំលៀកបំពាក់ ក្នុងបន្ទប់ធំនៅសល់តែបុរសគម, បេទ្រឌិន ហស្សននឹងបាវព្រាវពីរបីនាក់ ។ បុរសគមកើតសេចក្ដីក្ដៅក្រហាយខ្លាំង ដោយឃើញបេទ្រឌិនហស្សនក្រាញនៅក្នុងបន្ទប់ មិនព្រមចេញទៅដូច្នោះ នាំឲ្យចង្អិលសង្ស័យ ទើបស្រឡាំងសំឡក់ហើយបណ្ដេញថា "នែអ្នកនេះ, អ្នកឯងនៅចាំអី? ម្ដេចក៏មិនចេញទៅក្រៅដូចអ្នកឯទៀត? ចៀសចេញឆាប់ៗទៅ" ។ បេទ្រឌិន ហស្សន គ្មានអំណាចក្ដីនឹងនៅក្នុងបន្ទប់នោះ ក៏ចេញទៅទាំងទើមទាមសល់រវល់ក្នុងចិត្ត, ប៉ុន្តែចេញទៅមិនទាន់ផង

ផុតហួសពីពេលត្រូវចុះស្រៀវនេះ ស្រាប់តែបិសាចនឹងនាងទេពអប្សរមួយ ឈរកើនស្កក់មុខហើយបិសាចសួរថា «អ្នកចេញទៅឯណាវិញ? មិនត្រូវចេញទៅណាទេ, នៅត្រង់ទីនេះហើយ, ឯការតមនោះមិនបានទៅត្រង់ចន្លប់ទេ, ព្រោះជាទីងងឹតមានភ្លើងហេតុចេញទៅក្រៅឡើយហើយ, អ្នកត្រូវតែត្រលប់ទៅវិញហើយចូលទៅឲ្យដល់ត្រង់ចន្លប់ប្រពន្ធ កុំបីកោតញញើតឡើយ» កាលបើត្រលប់ទៅបួសស្ងាត់តែពីរនាក់ហើយ អ្នកត្រូវនិយាយប្រាប់នាងថា ខ្លួនអ្នកហ្នឹងឯងហើយជាប្ដីពិតប្រាកដ; — ថាព្រះពុទ្ធារដែលខ្ទង់ផ្ដើមបុរសគមឲ្យជាប្ដីរបស់នាងនោះ គ្រាន់តែជាកិច្ចបំភ្លឺលេងកំសាន្តព្រះទ័យប៉ុណ្ណោះ មិនមែនឲ្យធ្វើជាប្ដីពិតប្រាកដទេ; រួចហើយប្រាប់នាងទៀតថា ការតមនោះ ក្នុងវេលានេះអ្នកឯងបានឲ្យគេរៀបចំ ។ បានយកទៅឲ្យពស់ស៊ីត្រង់កន្លែងឯណោះដើម្បីកុំឲ្យកាត់ចិត្តពេក ។ អ្នកត្រូវនឹកគេខ្លាចផ្សេងៗទៀត និយាយល្បួងនាងយ៉ាងម៉េចឲ្យតែខាងបានជឿជាក់ប្រាកដ; កាលបើបានធ្វើឧបាយកលយ៉ាងនេះហើយ, ការនោះមិនមែនជាគ្រលំបាកអ្វីទេ នាងមុខជានឹងបានរីករាយដោយយល់ឃើញថា ការដែលនាងការប្រែឡូវនោះនាំឲ្យបានសប្បាយទៅវិញទេតើ ។ អ្នកកុំភ័យឲ្យសោះ មិនអីទេ. ត្រង់ពេលនោះខ្ញុំនឹងដាក់កាញ្ជបញ្ជាប់កុំឲ្យការតមចូលទៅបាន ហើយកុំឲ្យវាចូលទៅរំខានរឿងរ៉ាវអ្នក

ដែលកំពុងនៅជាមួយប្រពន្ធកូនក្រី ព្រោះនាងនោះពិតជាប្រពន្ធអ្នក ហើយ មិនមែនរបស់តាគមទេ" ។

គ្រាដែលបិសាចបាននិយាយកំឡាលើកទឹកចិត្ត បេះដូងខ្ញុំ ហាស្រែនកុំឲ្យកើតភ័យ មិនបានពន្យល់ទុបាយគលដូច្នេះហើយ បុរសគម ក៏ចេញមកអំពីបន្ទប់ធំ ។ បិសាចចូលទៅប្ដូរហើយ ដណ្ដើមខ្លួនជាធ្មា ខ្មៅធំ ស្រែកនាំៗ គម្រាមចង្វាចបុរសគមៗ ឃើញដូច្នោះ ក៏ទះដៃ ស្រែកដេញបង្អើល, ប៉ុន្តែធ្មាមិនរត់ បែរជាដំឡើងក្រចកក្រញាំង ហើបកន្ទុយខមក្រឡោតសំឡឹងសំឡក់បុរសគម ស្ទើរតែនឹងស៊ីសាច់ ។ ស្រែកគម្រាមខ្លាំងឡើងៗ ហើយពង្រីកខ្លួនឲ្យធំបន្តិចម្ដងៗ ពាល់តែប៉ុនកូនលា ។ បុរសគមភ័យខ្លាំងណាស់ រៀបនឹងហាមាត់ស្រែកហៅឲ្យគេជួយ, ប៉ុន្តែ ពៅស្រែកពុំរួច គ្រាន់តែឈរពោមាត់ប្រឹងហាដោយសេចក្ដីភ័យតក់ស្លុត ស្ទុតស្រឡាំងកាំងកាំងស្មារតី; ដើម្បីធ្វើឲ្យរិតតែភ័យខ្លាំងឡើងទៀត បិសាចតាំងត្រឡប់ខ្លួនក្លាយទៅជាក្របីយ៉ាងធំសម្បើម ហើយស្រែកបំភ័យថា "អាគមពោលម្សៀត! អញវែសម្លាប់ឯងហើយ!" ។ ឮពាក្យដូច្នោះហើយ បុរសគមដួលខ្ទាកទៅលើការ យកការងារគ្រប ក្បាល ដើម្បីកុំឲ្យមើលឃើញក្របីនោះ, ខំប្រឹងរង្វើយទាំងញញ័រញញ័រ ថា "បពិត្រលោកជាស្ដេចមហិទ្ធិ, ចុះលោកសួរខ្ញុំបាទពីរឿងអី?" ។ បិសាចតបភ្លាមថា "គ្រោះធំហើយអាឯង! អាឯងព្រះហរិនចិត្តធំហ៊ានមក

រៀបការខ្លួនជាមួយនឹងលោកស្រីឃើញ! ។ បុរសគមរំអង្គុរករថា "ខ្ញុំលោកម្ចាស់ថ្លៃអើយ, តាម តែលោកមេត្តាគន់ទោសឲ្យទាន: ប្រសិនបើខ្ញុំបាទជាមនុស្សគ្មានទោសធ្ងន់គំនិតមិនខែមនព្រោះការព្រហើនចិត្តធំទេ គឺដោយសេចក្តីល្ងង់ខ្លៅពិតៗ ខ្ញុំបាទមិនដឹងជាស្រីនេះមានប្តីជាគូស្នេហាទេ; បើខ្ញុំបាទខុសត្រង់ដូចម្តេច សូមលោកបង្គាប់តាមសេចក្តីពេញចិត្តចុះ, ខ្ញុំបាទនឹងទទួលប្រតិបត្តិតាមទាំងអស់" ។ បិសាចឆ្លើយទ្រឹងថា "ត្រូវស្លាប់! បើអាឯងចេញពីទីនេះទៅ ឬបើមិនទៅឲ្យស្ងៀមហួតដល់ថ្ងៃនេះទេ, តាំងនោះសោតបើអាឯងហើបមាត់និយាយពាក្យអ្វីតែមួយម៉ាត់ អញនឹងវាយបំបែកក្បាល ។ ណ្ហើយចុះ អញអនុញ្ញាតឲ្យអាឯងចេញទៅពីផ្ទះនេះ, ប៉ុន្តែត្រូវចេញឲ្យហើសកុំងាកក្រោយឲ្យសោះ ប្រសិនបើអាឯងហ៊ានតែងាកក្បាលមកវិញ អញនឹងផ្តាច់ជីវិតអាឯងភ្លាម ឥតបង្អង់" ។ លុះនិយាយដូច្នេះហើយ បិសាចក៏ប្រែកាយទៅជាមនុស្ស ចាប់ជើងបុរសគមយួរឡើង សំពងក្បាលចុះក្រោមហាក់ដូចជានឹងទ្រាត ផ្តួលនឹងផ្ទាំង ហើយគម្រាមបន្ថែមទៀតថា "បើអាឯងនៅមិនស្ងៀមទៅទល់នឹងថ្ងៃនេះទេ, ដូចអញបានថារួចមកហើយ, អញនឹងចាប់ជើងគក់គោះបោកបំបែកក្បាលនឹងផ្ទាំងនេះពុំខាន ។

ចំណែកខាងប៉េទ្រុងឌិនហស៊ុន, កាលបើបិសាចនឹងនាងទេពអប្សរនិយាយបាក់ដើនក្រមៀញចិត្តដូច្នេះហើយ, ក៏ចូលទៅវិញអង្គុយនៅតាំងចាំស្តាប់ដំណើរការរបស់ខ្លួន; មួយស្របក់ ទើបឮខាងសំឡក់ ទាំងប្រពន្ធមកបញ្ចូលក្នុងបន្ទប់នោះហើយ ខ្លួនគាត់មិនបានចូលទៅផងទេ ឈរតែក្បែរមាត់ទ្វារ ឥតបានពិនិត្យមើលថាគឺជាបុរសគម ឬក៏បុរសឯទៀតឡើយ គ្រាន់តែនិយាយឲ្យដំបូន្មានដល់ប្ដីថា ត្រូវខ្លួនធ្វើតាមប្រវេណីស្វាមីភរិយា តាមសេចក្ដីប្រាថ្នាចុះ ហើយគាត់បិទទ្វារវិលត្រឡប់ទៅវិញទៅ ។

នាងជាភរិយាមានសេចក្ដីជឿងងល់ណាស់ ព្រោះមិនឃើញបុរសគម តែបែរជាឃើញឯប៉េទ្រុងឌិន ហស៊ុនទៅវិញ ដែលជាបុរសប្រកបដោយគុណសម្បត្តិយ៉ាងឯកក្នុងលោក ទើបនាងសួរថា "នែអ្នកប្រុសសំឡាញ់, ម្ដេចក៏អ្នកមកនៅក្នុងបន្ទប់នេះតាមកំណត់ម៉ោង, ហេតុដូច្នេះ អ្នកត្រូវជាគូកនស្វាមីខ្ញុំឬ?" ប៉េទ្រុងឌិន ហស៊ុន តបថា មិនមែនទេនាង, ខ្លួនខ្ញុំនេះ មានឋានៈផ្សេងពីតាគម អប្រិយនោះទេ ។ នាងនិយាយឡើងថា "សូមអ្នកប្រយ័ត្នកុំនិយាយការក្រក់ពីស្វាមីខ្ញុំ ។" ប៉េទ្រុងឌិន ហស៊ុន តបថា នែនាង, ពាក្យជាប្ដីរបស់នាងមែន! នាងមានគំនិតយល់ដូច្នេះ យូរយារណាស់ហើយឬ? មិនមែនទេ នាងកុំការប្រឡំ, ធម្មតាជាតិស្រីគ្រប់លក្ខណ៍ប្រពៃហាក់ដូចនាងមិនត្រូវទៅរួមរស់នាជាមួយនឹងមនុស្សអប្រិយដូចបោក ដែលអ្នកផងគេស្អប់ខ្ពើមដូច្នោះ

ឡើយ, ខ្លួនខ្ញុំឯណោះទេ គឺដែលជាមនុស្សជាន់ខ្ពស់មានកំពូលសំណាង គួរនឹងយកជាប្ដីយ៉ាងនេះស្រីគ្រប់លក្ខណ៍បាន, ព្រះករុណាដែលទ្រង់យកតាមមកផ្ដុំផ្គុំឲ្យជាប្ដីនាងនោះ មិនមែនឲ្យធ្វើជាប្ដីមែនទែនទេ គឺទ្រង់គ្រាន់តែសព្វព្រះរាជហឫទ័យ បង់កំសាន្តចំពោះលោកឧត្តមមហាសេនាជាបិតារបស់នាងប៉ុណ្ណោះ ហើយទ្រង់បានជ្រើសរើសផ្ដុំផ្គុំខ្ញុំឯណោះទេ ដែលឲ្យជាប្តីពិតប្រាកដ, ដូចនាងបានសំគាល់ឃើញស្រាប់ហើយតើ ពួកស្រីៗ, ពួកអ្នកក្មេង, អ្នកបម្រើ, ទាសីរបស់នាងព្រមទាំងមនុស្សក្នុងផ្ទះនាងទាំងអម្បាលម៉ាន គេសប្បាយរីករាយណាស់ចំពោះកិច្ចការដែលព្រះករុណាទ្រង់ផ្ដុំផ្គុំបញ្ជាក់លេងនោះ, ឥឡូវនេះ ខ្ញុំដេញតាមមកប្រាប់នាងឲ្យបានច្បាស់ទៅហើយ ក៏តពុំតែស៊ីទៗ បាននៅក្នុងរោងសេះឯណោះ, សូមនាងជឿជាក់ចុះថា កាស្របលែងអើតក្បាលមកឲ្យនាងឃើញទៀតហើយ"

ពីគាលោកឧត្ដមមហាសេនា បានឮបេទ្រ ឌិន ហស្សន និយាយដូច្នោះហើយ ក៏ចូលទៅក្នុងបន្ទប់ផ្ទះដំណេកទាំងកាន់កាំងស្មារតី ស្លឹងស្លត់ពេក ព្រោះរឿងនេះការផ្ទួនឡើងមានទំនងដូច្នេះសោះ ហើយដែរត្រឡប់ទៅជាដូច្នោះវិញ នាងប្រែទឹកមុខភ្លាម ញញឹមស្រស់បំព្រងមើលទៅរឹតតែល្អឡើងៗ នាំឲ្យបេទ្រ ឌិន ហស្សនមានសេចក្ដីស្នេហាក្រៃកាន់ជាទីបំផុត ។ នាងផ្ដើមនិយាយឡើងទៀតថា "ខ្ញុំឥត

សង្ឃឹមថា ខ្លួនខ្ញុំនឹងបានសប្បាយដល់ម្ល៉េះហោះ, បានដាក់ផ្ទះផ្ទៃខ្លួន រួចស្រេចមកហើយ ថាមុខជានឹងនឹកក្ដុកសម្លុះជាតិគុំគាន, ប៉ុន្តែ ហេតុតែកំពូលកំណាន់ខ្ញុំជឿនខ្ពង់ខ្ពស់ណាស់ ទើបបានមកកប់ប្រសប់នឹង អ្នកបងដែលជាមនុស្សមានគុណសម្បត្តិវិសេស ជួបដល់សេចក្តីស្នេហា យ៉ាងថ្មីថ្មរបស់ខ្ញុំ" ។ ចាន់និយាយបណ្តើរ ដោះសំលៀកបំពាក់ ស្រាបណ្តើរ ហើយក៏ប្រះខ្លួនចំពេះទៅលើគ្រែ; ឯបេទ្រូទឹងបាសង្រែន នៅតែក្បែរកានីនាន ពេញហៅមហាសប្បាយស្ទើរតែណ្តកគតាក្ត ដោយ ឃើញខ្លួនឯងបានជាម្ចាស់នៃស្រីគ្រប់លក្ខណ៍ ដែលគួរស្នេហាយ៉ាង ក្រៃលែង, ម្នីម្នាដោះខោ អាវគ្រាដាក់លើកៅអីទីងលើចង់ប្រាក់ ដែលចៅកែជាតិស្ទើហ្វបានឲ្យមក; ចង់នោះគោះបីបានដកយកប្រាក់ តែកឲ្យគេប្រើនណាស់ទៅហើយ ក៏នៅតែពេញណែនទៅទៀត; បាន ដោះទាំងផតក្បាលរបស់ខ្លួនចេញ ចុះផ្តតមួយទៀតសម្រាប់ប្រើក្នុង ពេលយប់ ដែលគេបានរៀបចំបំរុងឲ្យបុរសគម រួចហើយក៏ទាំងពេក ខ្លួនលើគ្រែនៅតែការទ្រនាប់ខ្នើយខាខ្លីប៉ុណ្ណោះ ។ ខោខ្លីធ្វើពីសំពត់ ឡាញ់ពណ៌ខៀវ ហើយចង់រួតដោយខ្សែធ្វើពីខ្សែយឺតមាស ។

និយាយមកដល់ត្រង់នេះ លោកសេនាបតីយ៉ាំហ្វាំបញ្ចាក់ឡើង ទៀតថា: កាលដែលគូស្នេហាកំពុងដេកលក់ស៊ប់ស្ងួន បីសាចនិយាយ ចិនទាំងពេកគប្បថា "យើងត្រូវធ្វើកិច្ចដែលយើងបានត្រៀមជកប

ដល់ពេលនេះ ឲ្យហើយសព្វគ្រប់ទៅកុំបន្ទន់ឲ្យស្រណោះទាន់ ប៉ូទាន
ទៅលើតាបេទ្រូចិន ហាស៊ីន ជួមៗ កុំឲ្យភ្ញាក់ ។

នាងទេពអប្សរចូលទៅក្នុងបន្ទប់អ្នកតាំងពីកំពុងដេកលក់ស៊ប់ លើក
ក្រគនបេទ្រូចិន ហាស៊ីន ដែលមានតែការទ្រាប់ទំនើរខ្ញុំ ហើយ
ហោះទៅជាមួយនឹងបិសាច មានល្បឿនយ៉ាងលឿនហោះឥតឈប់ឈរ
រហូតដល់ទ្វារក្រុងជាមាសប្រះទេសស៊ុំ ទៅដល់កន្លែងនោះត្រូវបំលើ
ពេលដែលពួកទេវត្តមហាម៉ងកំពុងតែស្រែកប្រកាសជាសមណ្ណាជន ឲ្យ
ក្រោកឡើង ដើម្បីប្រជុំគ្នាសូត្រធម៌ ក្នុងបុព្វណ្ហសម័យ[១] ។ នាង
ទេពអប្សរក៏ដាក់បេទ្រូចិន ហាស៊ីន សន្សឹមៗទៅលើប្រថពីក្បែរទ្វារ
ក្រុង ហើយទើបរៀបចុះទៅជាមួយនឹងបិសាច ។

កាលគេបើកទ្វារក្រុងភ្លាម, ពួកបណ្ដាជនដែលប្រជុំគ្នាច្រើនណាស់
ណាខ្លាំងតាប់តុងនឹងបេញនោះ ស្រាប់តែភ្ញាក់ព្រឺតមានសេចក្ដីងឿង
ឆ្ងល់ណាស់ ព្រោះគេគ្រាន់តែបើកទ្វារភ្លាមឃើញបេទ្រូចិនហាស៊ីន
ដែកដួល នៅជិតស្រុកស្ងួតប្លាស់ទីនីដីហើយមានតែការទ្រាប់ទំនើរខ្ញុំ
ប៉ុណ្ណោះ ។ អ្នកខ្លះនិយាយថា «ឱ! ចៅពាលជាន្លាចេញពីផ្ទះទៅហ្វាយ
ឆ្ងាយ ដោយប្រញាប់ប្រញាល់ណាស់យ៉ាងម៉េច បានជាកេកការ
ស្ទើរទាក់ឲ្យស្រួលបួលមិនទាន់» ។ អ្នកខ្លះទៀតឆ្លើយឡើងថា «ប៉ូទាំ

១ ព្រឹក, ព្រលឹមស្រាងៗ ។

គ្នាពិនិត្យមើលសំនៀវក្រឹះ លាគ្នាមានគ្រោះថ្នាក់ទេ ។ ទំនងជាដើរលេងស៊ី
ផឹកជាមួយទីងគុកខែប្រែនគ្នា, ដល់ស្រវឹងតែគគោខ្លាំង ចេញទៅខាង
ក្រៅដោយមានកំហុសអ្វីមួយ ហើយក្រឡប់ចូលមកវិញមិនទាន់គេបិទទ្វារ
ទេ កំមគទេវមាត្រឹមមាត់ទ្វារនេះ ជួលដេកសន្លឹងសន្លប់មិនដឹងខ្លួន
ប្រាណ ព្រោះស្រវឹងផុលហើយយ៉ាងមើល" ។ ពួកជនទាំងនោះ
និយាយស្មានមិនត្រូវគ្នាសោះ ខ្លះថាដូច្នេះ, ខ្លះថាដូច្នោះ, កែនរណា
មួយតាមដើម ហេតុដែលបេព្រៃនឹង ហស្បែន មកដេកនៅត្រង់កន្លែង
នោះឲ្យត្រូវចំពិតប្រាកដពុំបានឡើយ ។ ពេលនោះមានខ្យល់បក់
រំភើយៗ មក, ក៏ផាត់គាវព្រៃទាប់ម្នាក់បេញបន្តិច, គេមើលឃើញដើម
ទ្រូងបេព្រៃនឹង ហស្បែនសស្គុះ ហើយគេណាន់មាត់ត្រប់គ្នាដោយមាន
សេចក្តីចំឡែកខ្លួនឆ្ងល់; មុរសក៏ភ្ញាក់ឡើងភ្លាម ព្រោះឮសំឡេងរំពង
របោះអ្វីៗនោះឯង ហើយស្រឡាំងកាំងងឿងឆ្ងល់ពេក ដោយឃើញ
ខ្លួនឯងមកនៅក្បែរព្រះទីក្រុង ដែលខ្លួនមិនដែលបានមកម្តងសោះ ហើយ
ឃើញបណ្តាជនមីរដេរដាសឈរតំរួតតាមពេមជុំជិត ពិនិត្យមើលឈ្លប
យ៉ាងនេះ ទើបងើបមុខមើលគេមើលឯងទាំងស៊ីងមង៉ឹង ហើយសួរថា

(មានត)

រឿងស៊ុន យ៉ាត-សេន

# អ្នកនយោបាយឯក កាលជាប់ឃុំនៅក្រុងឡុងដ្រ៍

លោក ពុយ-ប៊ុក ប្រែពីភាសាបារាំង

(តទៅ)

---

ជាក់ទៅនៅក្រោមបង្អួចបន្ទប់ខ្ញុំ ៗ និយាយសុំឲ្យអ្នកបំរើរើសយកមកឲ្យខ្ញុំ ៗ ពួកបំរើមិនព្រមធ្វើតាមថែមទាំងចាក់ឲ្យទាហានជនរើសប្រមូលសំបុត្រលើដំបូលផ្ទះយកទៅឲ្យចៅហ្វាយរក្សាទាំងអស់ ៗ រួចគេបានបិទបង្អួចបន្ទប់ខ្ញុំជិតស្លុង ហាំងពីពេលនោះមក ខ្ញុំមិនអាចប្រាស្រ័យចេញទៅក្រៅបានឡើយ — ខ្ញុំគិតតែប្រមល់ក្នុងចិត្តលែងមានសង្ឃឹមតទៅទៀត ហើយមានតែផ្លូវ១ គឺបន់ស្រន់ព្រះជាម្ចាស់ ដើម្បីឲ្យព្រះអង្គជួយសង្គ្រោះដល់ខ្ញុំក្នុងគ្រាក្រជាបំផុតនេះ ៗ

ថ្ងៃសុក្រព្រឹក ១៦ ឧកតូប្រ៍ ខ្ញុំក្រោកពីដេកឡើងចិត្តគំនិតក្ដីស្រឡះខិតសង្ឃឹមទុកចិត្តខ្លួនថា ពាក្យដែលខ្ញុំបន់ស្រន់ព្រះអង្គ បានបន្ទន់ព្រះទ័យព្រះអង្គឲ្យទ្រង់ព្រះមេត្តា ទ្រង់យល់ព្រមមកជួយដោះទុក្ខខ្ញុំក្នុងពេលនោះមែន ៗ ខ្ញុំក៏ពុំបានលះបង់សេចក្ដីព្យាយាម បានហៅឈ្មោះកូល (cole) ឥតប្រាប់ថា ឲ្យជួយសង្គ្រោះខ្ញុំផង ៗ ឈ្មោះកូលក៏សួរមកខ្ញុំវិញថាអ្នកឯងជាអ្វី ? — ពួកអ្នកធ្វើនយោបាយនៅប្រទេសចិនហើយបានរត់មកជ្រកកោននៅទីនេះ ៗ

ខ្ញុំស្មានថា ឈ្មោះគូលបស្គាល់ចិត្តខ្ញុំមិនសូវបាន ទើបខ្ញុំប្រាប់ទៅឈ្មោះគូលវិញថា អ្នកឯងធ្លាប់បានឮគេនិយាយពីជាតិអារមេនីយ៉ាន់ឬទេ ?— ឈ្មោះគូលបក៏តបមកវិញដោយឥតគ្រាប ។ ខ្ញុំក៏និយាយតទៅទៀតថា ដូចជាពួកស្តេចសុលតង់នៃទួរគី ដែលឲ្យប្រហារជីវិតពួកអ្នកកាន់លទ្ធិគ្រិស្តសាសនា ។ ព្រះមហាចក្រពត្តិទ ក៏ចង់បង្ហាប់ជីវិតខ្ញុំដូច្នោះដែរ ពីព្រោះខ្ញុំជាអ្នកកាន់លទ្ធិគ្រិស្តសាសនា ហើយជាសមាជិកពួកសង្គមដែលមានបំណងនឹងកែប្រែដោកិច្ចាលជនឲ្យវិសេសល្អតទៅ ក្នុងអនាគតកាល ។

ពួកជាតិអង់គ្លេសតែងមានចិត្តករុណាតសាសូរដល់ជាតិអារមេនីយ៉ាន់ ខ្ញុំឥតជឿនិងឆ្ងល់ទេ ប្រសិនបើពួកជាតិអង់គ្លេសបានឃើញស្ថានភាពរបស់ខ្ញុំក្នុងពេលនេះ ប្រហែលជាលោកបានពិតករុណាតសាសូរដល់ខ្ញុំដូច្នោះមិនខានទេ ។

ខ្ញុំនិយាយតទៅទៀតថា ជីវិតខ្ញុំនៅលើដៃអ្នក បើអ្នកករុណាអោយករឿងខ្ញុំទៅផ្សាយចេញក្រៅ ខ្ញុំក៏នឹងបានរស់ជីវិត. បើមិនធ្វើដូច្នេះទេ ខ្ញុំមុខជាត្រូវគេប្រហារជីវិតហើយ ។ ក្នុងរឿងដូច្នេះកិច្ចណាជាទុក្ខគតិរបស់អ្នក ឬប្រតិបត្តិតាមករណីយកិច្ចរបស់អ្នក ចំពោះព្រះជាម្ចាស់ ខ្ញុំសូមឲ្យអ្នកគូលពិចារណាពាក្យ ដែលខ្ញុំបានជម្រាបមកនេះចុះ ដល់អ្នកត្រឡប់មកវិញក្រោយសឹមឆ្លើយប្រាប់ខ្ញុំ ។

ឈ្មោះគូលក៏ចេញពីបន្ទប់ទៅ ដល់ព្រឹកស្អែកឃើញគាត់វិលមកវិញ - ពេលនោះឈ្មោះគូលកំពុងដាក់ធ្យូងទៅលើភ្លើង បានបង្ហាញខ្ញុំឲ្យយកក្រដាសមួយដែលគាត់បានដាក់លើជើងក្រានធ្យូង - ដល់ឈ្មោះគូលចេញផុតពីបន្ទប់ទៅខ្ញុំក៏រើសយកក្រដាសនោះមកមើលថា :

“ខ្ញុំបង់យកសំបុត្រ ១ ទៅឲ្យមិត្តលោក តែកុំឲ្យលោកសរសេរសំបុត្រនោះលើតុ ដ្បិតគេបានឃាំមកលបមើលតាមប្រហោងសោទ្វារ ឲ្យលោកសរសេរលើគ្រែដេកវិញ” ។

ខ្ញុំក៏ព្រាលសរសេរបែរមុខទៅខាងជញ្ជាំង ខ្ញុំយកនាមប័ត្រ (Carte de visite) សរសេរទៅលោកគន់ឌី ។ ដល់ថ្ងៃត្រង់ឈ្មោះគូលចូលមកដល់ ខ្ញុំក៏យកចង្អុលដៃបង្ហាញអ្នកគូល ។ ក៏រើសយកសំបុត្រនោះ ហើយខ្ញុំក៏ជូនប្រាក់ទាំងអស់របស់ខ្ញុំទៅគាត់ ប្រហែល ២០ “លីវ្រ” ។ សំបុត្រដែលលោកគន់ឌីផ្ញើមកខ្ញុំវិញ ឈ្មោះគូលបានយកទៅដាក់ក្រោមជើងក្រានធ្យូង ។ គាត់បានចោលកន្ទបកែ្លកឲ្យសញ្ញាខ្ញុំ ៗ ក៏ស្ទុះទៅរើសយកមើល ខ្ញុំមានចិត្តត្រេកអរណាស់ ដែលបានឃើញសេចក្ដីក្នុងសំបុត្រនោះថា: “ខំអត់ធ្មត់បន្តិចទៅ រដ្ឋាភិបាលកំពុងតែរកការឲ្យលោក ពីរ-បីថ្ងៃក្រោយលោកផុតទុក្ខទៅហើយ” ។

ខ្ញុំក៏បានដឹងច្បាស់ថាព្រះជាម្ចាស់ដែលខ្ញុំបានបួងព្រះគុណទ្រង់បានមកជួយខ្ញុំមែន ។

ពីថ្ងៃមុន ខ្ញុំមិនដែលផ្លាស់សំលៀកបំពាក់ ជួនកាលខ្ញុំនឹងដុយដេក ដែរ តែចិត្តរើករាយ ។

ដល់ខ្ញុំទទួលដំណឹងពីកល្យាណមិត្ត ទើបនាំឲ្យខ្ញុំសប្បាយចិត្ត ខ្ញុំបានទទួលអាហារបរិច្ចាគ - ខ្ញុំខ្លាចបរាជ័យក្នុងការតក់រឿងនេះ បើប្រសិនណាពួកចិនបានយកខ្ញុំត្រឡប់ទៅស្រុកចិនវិញ ពួកនោះបានចុះផ្សាយគ្រប់ទំព័រថា រដ្ឋាភិបាលអង់គ្លេសនេះបោះបង់ចោលខ្ញុំ ជៀសនៅកម្មការអង់គ្លេសពួកអ្នកចុះផ្សាយពុំអាចនឹងមកពឹងពាក់ការស្រវ័យបានទេ ។ ពួកសមាជិកភាគ “គណបក្ស” គេបានប្រាប់រឿងដែលអង់គ្លេសបានប្រើនយោបាយក្នុងការបណ្តាលពួក “កែពីន” ហើយដោយសារជាតិអង់គ្លេសបានជួយទំនុកបម្រុងបានជាបំផ្លាញ នូវមហាបដិវត្តិស្នេហាជាតិពួកដែលកាន់លទ្ធិ (Catholique) គឺពួក “កែពីន” នេះឲ្យវិនាសទៅបាន ។ ដល់គេយកខ្ញុំមកប្រទេសចិន ខ្ញុំប្រហែលជាគេប្រហារជីវិតចង់ដោយយល់ថាបដិវត្តិនេះ គឺជាតិអង់គ្លេសបានធ្វើឲ្យស្ងប់ស្ងាត់ទៅហើយ ហើយក៏ពួក “គណបក្ស” ក៏បោះបង់ចោលការនេះដោយឥតសង្ឃឹមថានឹងបានផលប្រយោជន៍តទៅអនាគត ។

បើជាគន្លងផ្លូវតែកបានក្រដាសខ្ញុំ មុខជាលំបាកចំពោះរឿងនេះ ព្រោះថ្នាក់នោះត្រឡប់វាមិនមានទៅវិញ ដោយសារមកជាមកដល់ថ្មី បានសុំបួសជីវិតក្លួលទៅគេហដ្ឋានដែលខ្ញុំនៅ ហើយបានប្រមូលក្រដាស

ទាំងប៉ុន្មាន ដុតភ្លើងឆ្លងកាត់ទៅលេកសំគាល់ កដការបិទមេសំបុត្រ ស្នាមត្រាមិនឃើញល្អមឲ្យមានហេតុតាក់តែងគ្មានទីពួកម៉ាចខ្ញុំនោះ ។

ខ្ញុំមិនបានគិតគន់ពេលនោះថា ម្ហូបអាហារដែលគេឲ្យខ្ញុំបរិភោគ លាយថ្នាំពុលពិតទេ តែដោយខ្ញុំកន្លល់ក្នុងចិត្តខ្ញុំមិនបានទទួលទានទៅភោ-ជនាហារនោះសោះ ខ្ញុំគ្រាន់តែទទួលទានទឹកដោះគោ, តែ, នំបុ័ងពាល ពន់ទាន់មួយ ល្មះគ្រាតែសំបុត្រពួកម៉ាចខ្ញុំមកដល់ឲ្យដំណឹងដល់ថ្ងៃថានោះ ទើបខ្ញុំបរិភោគអាហារទទួលទានដំណេក ឥតមានគិតភ័យអ្វីទៀយ ។

## ស្ថានការនៃមិត្តភក្តិខ្ញុំក្នុងរឿងនេះ

ខ្ញុំឥតបានដឹងអ្វីសោះ ទូរហេតុខាងក្រៅទេ គឺដែលខ្ញុំដឹងគឺ សំបុត្រទាំងប៉ុន្មានរបស់ខ្ញុំ បានប្រគល់តាមអ្នកផ្សារទៅលោក សៀវហេញ្ញ៉េវម៉ារគាឌី ។

កាលថ្ងៃសុក្រ ១៦ អុកតូប្រ៍ ពេលព្រឹកខ្ញុំមានសង្ឃឹមដោយឃើញ «កូល» ជាបម្រើជាតិអង់គ្លេសទៅកន្លែងនោះបានយកចិត្តឈ្លាប ចំពោះខ្ញុំ ភរិយាអ្នក «កូល» បានជួយចេញគ្រប់កិច្ចការនេះ ពាល់តែបាន សម្រេច គឺភរិយាអ្នក «កូល» នេះ បានសរសេរសំបុត្រទៅលោកចន់ទ្វី ពីថ្ងៃសៅរ៍ ១៧ អុកតូប្រ៍ ១៨៩៦ ហើយក៏រៀបចំដំណើរនេះឲ្យប្រព្រឹត្ត ទៅបានតាមបំណង-សំបុត្រនោះទៅដល់ផ្ទះ ឌី វិនសៀរ (Devonshire)

ម៉ោង ១០ ព្រឹក ប៉ៅយ៉ើងនឹកគិតក្នុងចិត្តថា លោកកង់ទ័រ បានមើលសេចក្តី

ក្នុងសំបុត្រហើយ មានស្មានការពាវែពយ៉ាងណាទៅ?

«មានមិត្តភ័ក្តិលោកម្នាក់ជាប់ឃុំឃាំងនៅក្នុងស្ថានអគ្គរាជទូតចិន តាំងពីថ្ងៃអាទិត្យ គេបង់នាំគាត់ទៅតាមនាវាក្រឡុងទៅប្រទេសចិនវិញ ហើយគេក៏ប្រហារជីវិតបង់ គួរឲ្យអាណិតបុរសកំសត់នោះពន់ពេក បើគ្មានអ្នកណាតវ៉ាទេ គេមុខជានាំគាត់យកទៅហើយ នៅទីនេះមិនមានអ្នកណាដឹងរឿងគាត់ឡើយ - ខ្ញុំមិនចុះហត្ថលេខាទេ - តែការដែលខ្ញុំដំណោយនោះពិត ហើយអ្នកត្រូវជឿខ្ញុំ បើអ្នកសព្រៃបចង់ណា ត្រូវតែក្តាមគន្លងយ៉ាំពេច ចេញជួយដោះទេ ការនោះនឹងខូចដោយធ្វើពុំទាន់ពេល តាមឈ្មោះមនុស្សដែលជាប់គុកនោះ គឺ លិន - យ៉ិន - សេង - (Lin-yin-Séng)

មិនត្រូវបង្អង់ ពេល វេលា ឡើយ ហើយក៏លោកកង់ទ័រចេញទៅរកម៉ាកខ្មែរលោកសៀវហោស៊ុងម៉ាការតេ - លោកបានឃើញគេហដ្ឋានមួយលេខ ៣ នៅស្ពានទីហាប៉ាយំតែបាប៊ិនដិតប្រហែលជាម៉ោង ១១ ដប់ប្រាំមាត់ល្ងាចថ្ងៃសៅរ៍ ពួកគាបានក្រែមទេ បាលមួយដែលយាមនៅទីនោះចេញមកឃុំមើលពួកមាតខ្ញុំដោយសង្ស័យក្នុងចិត្ត មិត្តទីបានស្ត្រីទាហាននោះៗថា គេហដ្ឋាននេះបានបិទទ្វារ ៦ ខែមកហើយ អ្នកម្ចាស់ផ្ទះបានទៅនៅឯស្រុកផ្សេង លោកកង់ទ័របានសួរទាហាននោះ (ទាត)

អំពីការសង្ឃទាន

# ប្រគល់មុខការព្រះសង្ឃនាយក

កាលពីថ្ងៃសុក្រ ១០ កើតខែផល្គុនឆ្នាំកុរ ឯកស័ក ព.ស. ២៥១៤ (១៩-៣-៧១), វេលាដែលព្រះអាទិត្យមានរស្មីជ្រេទន់ទ្រេត ទៅកាន់ទិសបស្ចិម ពេលម៉ោង ១៨ ជាវេលាមាននក្ខត្តឫក្សល្អ នៅទីសាលាបាលីរង វត្តឧណ្ណាលោម សង្កាត់លេខ ៣ ក្រុងភ្នំពេញ មានការរៀបចំពិធីសន្និបាត ១ ហៅថា "ពិធីប្រគល់មុខការព្រះសង្ឃនាយក" ដែលមានព្រះតេជព្រះគុណព្រះមហាវិមលធម្ម ពុង-គាត នាយកដឹកនាំការ-កិច្ចរៀបចំនេះ ។ ខាងមុខសាលាបាលីរង, ត្រូវរៀបចំតាំងតុមានលំអរៀបតាំងដោយផើងផ្កាស្រស់បំព្រងដែលដាក់បន្ទាត់ជាជួរ តាមបន្ទាត់បង្កាន់ដៃនៃជណ្តើរឡើងទៅលើ; ត្រង់មាត់ទ្វារធំខាងក្រៅនៃមាត់ទ្វារសាលាបាលីរង មានទង់ជ័យរូបប្រាសាទជាគូៗទម្លាក់ពីខាងលើ ហើយដែលបក់ទៅមកដោយខ្យល់ជាគួរមកពីទិសទាំងពួងជាតិច្បាស់ជាប់ៗ ខាងក្នុងសាលា, ត្រង់ផ្លូវកណ្តាលមានរៀបតុគ្រួយស ៣ សុទ្ធតែគ្របដោយកម្រាលមានពណ៌ស្អាតរបស់ប្រសើរថ្លៃថ្លា ៖ តុទី ១ ខាងកើត មានដាក់លំពែងផ្កាមានក្លិនក្រអូបឈ្ងុយឈ្ងប់ ដែលដាក់ទ្រដោយប្រដាប់សម្រាប់ដាក់ភួងផ្កា ។ ព្រមទាំងមានរៀបប្រដាប់ប្រដាគ្រឿង

សរសេរខ្លះទៀតផងនៅលើគុនោះ, គឺជាគុលប្រាប់ទុកឲ្យលោកអ្នកមាន
បណ្ដាស័ក្ដិធំ ៗ គុទី ២ តាំងនៅខាងលិចគុនេះ ជាក់បន្ទប់លើវេទិកា ១
ថ្នាក់ មានពានទ្រទិវមាស ក្ដប ធំ ១ គូ ក្រៅមកលើគាដកល់នៅលើគុនោះ
ហើយមានចាំងរំលេចដោយក្បាច់មានពណ៌.ផ្សេង ៗ នៅក្នុងពានទ្រទាំង
២ នោះផង ជាកុសលប្រាប់ដកល់ព្រៃព្រះសារីរិកធាតុ ទីងសប្រាប់ដំកល់
បញ្ញើមុខការផ្សេង ៗ ខ្លះទៀតផង ៗ គុទី ៣ ស្ថិតនៅខាងជើងគុទី ២
ជាកុសលប្រាប់ឲ្យគេសង្ឃះផ្សេង ៗ នៅជើងញាំងទ្រខាងក្នុងសា-
លាកាតណ្ដាលដែលមានវិចិត្រដោយរូបគំនូរជាបែបភាគផ្សេង ហើយ
ដែលមានដំកល់ព្រះពុទ្ធរូបធំមិនញ្ញាក់ធំ ១ ព្រះអង្គ ទុកនៅទីនោះជាទីបូ-
ការេ ទុកដូចជាបូជនីយស្ថាន ១ ដ៏ប្រសើរ ក៏មានទៀតចំគ្រឿងពុទ្ធបូជា
មានកំរើក្ដាជាដើមសព្វគ្រប់ដែរ ។ កន្លែងដែលបានពុំទានផងទៀតចំនោ
ទីនេះតាំងពីបុរាណ ជាស្ថានភាពដ៏សមស្របល្អមគួរដល់ការ ទុកជាជា
ទស្សនីយដ្ឋាន ១ ដ៏ប្រសើរក្នុងការប្រជុំសន្និបាតនេះ ។ គោលនោះ
ព្រះបាទឡាក់សម៍ស ញូ ឧម ហេង វត្តសារាវ័ន (មេធាធិការនៃសម្ពុទ្ធ
ព្រះសារីរិកធាតុនៅលាវជាតិកាស់) បានបញ្ចូនមកទៀតនៅជា
ផ្សេង ៗ ពីក្នុងភាពរៀបរាបដល់ក្រុមគណៈលើគុទី ២ ដែលបានស្ថិតនៅក្នុងជើងញាំង
មានដំកល់ព្រះពុទ្ធរូប ។

ក្នុងគណៈនោះ មានព្រះសង្ឃរាជាគណៈ ហៅថានុក្រមជាច្រើនរូប បានទទួលមកកាន់ទីសន្និបាតនោះ គឺ :

ព្រះតេជព្រះគុណព្រះវនរ័ត ពេជ្រ - មឿន វត្តឧណ្ណាលោម

- ព្រះមហាវិមលធម្ម ហួត - តាត -
- ព្រះពុទ្ធឃោសាចារ្យ ទែន - ប៉ុល -
- ព្រះឧត្តមមុនី ពៅ - ទេព -
- ព្រះធម្មឃោសាចារ្យ អ៊ុត - គុប វត្តសារាវ័ន
- ព្រះសាក្យវង្ស ពៅ - ញាណ -
- ព្រះញាណសង្វរ ផង់ - កុយ -
- ព្រះធម្មវង្ស ពៅ - ហ៊ុន -

ព្រះគ្រូពោធិវង្សបរិយាព្រឹទ្ធ កប - គឹង -

ព្រះគ្រូបញ្ញាវិទូ ម៉ូង - បាន -

ព្រះគ្រូសាសនវង្ស គុយ - សូត្រ -

ព្រះគ្រូឧត្តមមុនីវង្ស កប - ជុំ -

ព្រះគ្រូបញ្ញាវិសុទ្ធ ជួន - ប៊ូ -

ព្រះគ្រូវិជិតសត្ថា គោ - ហង្ស -

ព្រះបាឡាត់សង្ឃវិជ្ជា គង់ - ហេង -

មានព្រះសង្ឃបាននិមន្តមកក្រៅពីនេះនឹងគ្រហស្ថអ្នកមានបុណ្យ-សទ្ធាច្រើនរូបទៀត មិនបាននាំយកនាមចុះក្នុងទីនេះទេ ។

ម៉ោង ១៥ និង ១៥ នាទី, លោកអ្នកឧកញ៉ាពិភក្តិសាសនៈ (ហ៊ុយ-ឧនល) រដ្ឋមន្ត្រីក្រសួងធម្មការ ក៏បានអញ្ជើញមកដល់តាមរថយន្តមួយ មានលោកនាយកមន្ទីរ (ម៉ៅ ហុកាបណាក់) ក្នុងក្រសួងនោះជូនដំណើរមកផង ។ បន្ទាប់មកទៀត, នាយមន្ត្រីរាជការក្នុងក្រសួងដែលនេះខ្លះ ទៀតអញ្ជើញមកដែរ ។ ព្រះសង្ឃគណនុគ្រោះគ្រប់រូបដែលនៅចាំទទួល លោកនៅទីនោះ ក៏អញ្ជើញលោកឧកញ៉ាពិភក្តិសាសនៈ និងអស់លោកមន្ត្រីរាជការទាំង ១ អង្គ ឲ្យទៅអង្គុយលើសាលាទានគ្រឿងឧបភោគ ដែលគេរៀបចំទុកប្រុងចាំទទួល ។ ព្រះសង្ឃគណនុគ្រោះទាំងអស់ ក៏និមន្តទៅគង់ទីផ្ទាល់ដីទំនាបខ្លះទៀត ។

លុះការសន្និបាតនោះស្ងប់ស្ងាត់ស្រួលបួលហើយ លោកអ្នកឧកញ៉ាពិភក្តិសាសនៈ ក្រោកឈរឡើង ហើយពោលសុន្ទរកថា ១ យ៉ាងក្បោះក្បាយ ដើម្បីស្រង់យកតែសេចក្តីសំខាន់មកចុះក្នុងទីនេះ ៖

សម្តេច [illegible] ការតាំងពោរព្រះសង្ឃគ្រប់អង្គ [illegible] សន្និបាតក្នុងទីនេះ [illegible] ព្រះមហា [illegible] សាកវិ [illegible] ព.ស. ២៤៩២ នេះ, [illegible] មហានិកាយ, តាម

ព្រះរាជក្រឹត្យ លេខ ២៥ ន.ស. ចុះថ្ងៃ ៤ មីនា គ.ស. ១៩៤៨ ត្រូវបានមកលើព្រះតេជព្រះគុណ ព្រះពោធិវង្ស ជួន-ណាត វត្តឧណ្ណាលោម ជាអ្នកទទួលតំណែងជាព្រះមហាសុមេធាធិបតីសង្ឃនាយកគណមហានិកាយតទៅ; វេលានេះ ត្រូវប្រគល់កិច្ចការព្រះសង្ឃនាយកនោះប្រគេនមកលោក ឱ្យព្រះគុណបានសោយសក្តិមហា ព្រះតេជព្រះគុណអង្គនេះជាអ្នកប្រាជ្ញប្រសើរដ៏ប្រាជ្ញខាងផ្សព្វព្រះពុទ្ធសាសនាគ្រប់វិជ្ជាផ្សេងៗ, លោកនឹងការពារគុណកំរុងរៀបចំព្រះពុទ្ធសាសនា ឱ្យចុះរបៀបមានលំនឹងដោយលឿនទៅកាន់សេចក្តីចំរើនបាន ។ .....

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

កាលចប់សុន្ទរកថានេះហើយ ព្រះតេជព្រះគុណព្រះមហាសុមេធាធិបតីសង្ឃនាយកថ្មី មានថេរដីកាថ្លែងតបសុន្ទរកថាលោកអ្នកទទួលកញ្ញាពិធីក្តីសាសនានោះវិញ ដោយសង្ខេប (មិនបានស្រង់មកចុះក្នុងទីនេះទេ)

លុះចប់ថេរដីកានោះហើយ លោកអ្នកទទួលកញ្ញាពិធីក្តីសាសនាបាន លើកយកពានស្លាស្រាប់ព្រះសង្ឃនាយក មកប្រគេនព្រះមហាសុមេធាធិបតីសង្ឃនាយក រួចហើយ បានចុះហត្ថលេខាក្នុងសៀវភៅបញ្ជីតាំង ប៉ុន្មានព្រមជាមួយនឹងព្រះបាឡាត់សង្ឃវង្សផង ប្រគេនមកលោកក្នុង

ខណៈនោះទៀត ។ ព្រះតេជព្រះគុណព្រះមហាសុមេធាធិបតីសង្ឃ-នាយក ក៏បានចុះហត្ថលេខាទទួលសៀវភៅបញ្ជីមុខការតាំងបុគ្គលនោះមកតាំងអស់ ។ បន្ទាប់មក ព្រះសង្ឃគ្រូអនុគ្រោះទាំងអស់បានសូត្រជយន្តោ មួយចប់ ជាជ័យមង្គលក្នុងពិធីនេះ ។

កាលបើស្រេចការប្រគល់មុខការព្រះសង្ឃនាយកនេះសព្វគ្រប់ហើយ លោកអ្នកឧកញ៉ាពិភក្តិសាសនៈបានសន្ទនាប្រស្រ័យទាក់ទងជាមួយនឹងព្រះសង្ឃគ្រូអនុគ្រោះទាំងនោះ អស់រយៈកាលជាសមគួរ, លោកបានប្រសាសន៍ប្រាប់ព្រះសង្ឃទាំងនោះ អំពីព្រះពុទ្ធសាសនាក្នុងប្រទេសយើងនិងប្រទេសនានាខ្លះ ជាលំដាប់ហូរហែ តាមដែលលោកធ្លាប់បានអញ្ជើញទៅឃើញ ។

ម៉ោង ១៩ និង ១៥ នាទី, លោកអ្នកឧកញ៉ាពិភក្តិសាសនៈព្រមទាំងអស់លោកមន្ត្រីក្រសួងធម្មការទាំងអស់ ថ្វាយបង្គំលាព្រះមហាសុមេធាធិបតីសង្ឃនាយកនិងព្រះសង្ឃគ្រូអនុគ្រោះគ្រប់អង្គ ហើយក៏អញ្ជើញត្រឡប់ទៅវិញ ។ ព្រះសង្ឃនិងគ្រហស្ថពាក់ព័ន្ធនឹងភេសជ្ជៈ បានរៀបចំភេសជ្ជៈប្រគេនព្រះសង្ឃគ្រូអនុគ្រោះទាំងអស់នោះនាទនគ្រប់ៗ រូប តាមសមគួរ ។ ក្រោយដែលបានឆាន់ភេសជ្ជៈរួចស្រេចបាច់ហើយ ព្រះសង្ឃគ្រូអនុគ្រោះអង្គណាដែលនិមន្តមកពីខេត្តក្រៅ ក៏ថ្វាយបង្គំលា

ព្រះមហាសុមេធាធិបតីសង្ឃនាយកទ្រង់ព្រះបញ្ញាជាគណៈខ្ពស់ ដែលគួរ
ណា និមន្តត្រឡប់ទៅកាន់ត្តលោកវិញ រៀងៗខ្លួន ជាសូរេបក្ខសន្និបាត
ប្រគល់មុខការព្រះសង្ឃនាយកត្រឹមតែប៉ុណ្ណេះ នៅវេលាម៉ោង ១៩
និង ៣៥ នាទី ។

សម្ភារពោធិញ្ញាណ ជួប-ឆៀន វត្តឧណ្ណាលោម
បានរៀបរៀងតាមដំណើរការណ៍ដែលបានឃើញ ។
ថ្ងៃ ២៩/៣/៤៨

# យុវចរិយាគាថា

## ព្រះគ្រូបញ្ញាលិខិត កៅ-ស៊ុម

### គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ទៀបទៀន

(តមក)

---

មិនមានគិតផល់គ្រឿងដែលគេរៀបរាក់ប៉ុណ្ណា ប្រែប្រួលព្រះពោរទៅលើ ស្ពានលើស្ពាន ប៉ះលើគន្លោះកំពប់គន្លោះ ប៉ះកើតផែនពានស្ពាន កំពប់ស្ពានព្រៃ ប៉ះលើផ្លូវទឹក ហៃទឹក កំពប់ផ្លូវទឹកហៃទឹក ពុះពារ សោតដាក់បន្ទុយចុះទៅលើផែនពានមាស ព្រាក់ ធាក់កញ្ចក់ផែនពាន នោះៗ ឬអន្ទិយក្លេកខ្នងកមានសក់សម្បូរញ ខិយាយកំសាំងខាយកាយ ទៅប៉ះគន្លោះកំពប់ចំកមាត់ប្រៀកក់កកស្ពា ពេញផ្ទុំទៅលើអាសនៈ មានគម្ពុជ ព្រំ បៀមដែលមានថ្លៃច្រើនជាដើម ជាហេតុនាំឲ្យពាយក អួលគកអន់ស្តាំ ពុំស្រូបមានផលានិសង្ស ដោយសារបញ្ជិតនោះៗ មិន សង្រួមឥន្ទ្រិយហេតុបច្ច័យកាត់ដេក-ដើរ-ឈរ-អង្គុយនោះៗ ។ សូមអញ្ជើញ មើលគម្ពីរមហាសតិបដ្ឋានសូត្រ ត្រង់សម្បជញ្ញបព្វៈពារណោះ ដែលមាន សេចក្តីព្រាលព្រៀងមកប្រើដាំខ្ញុំឲ្យច្បាស់ទៀតយ៉ាងនេះ ទៅជន្លុះ ៖ គពី នេះសូមស្តាប់ពាក្យពាក្យជាគ្រឿងជំនួយនៃសេចក្តីអធិប្បាយមកនេះ ។

# កាព្យពាក្យ ៧

អង្គុយកន្ទលគាល់គំនាប់ ឃើញអ្នកគួរបន្ទាប់មកដល់ភ្លាម ប្រុងកាយប្រុងចិត្តអង្គុយស្ងៀម រង់ត្រៀមកុំព្រោកពាលអ្នកធំ ។ អង្គុយឈរកុំឆ្ងាយជិតពេក បត់ជើង ២ ផ្គងដៃប្រណម្យ កិរិយាអង្គុយធ្វើឲ្យរម្យ រៀបចំឲ្យត្រូវច្បាប់អង្គា ។ មិនត្រូវអង្គុយឈរលើខ្យល់ រាយោបក់ដល់ចំកាយា អ្នកធំអង្គុយក្រោមកក់តា ពុំកុំខញើសសាពេញពីខ្លួន ។ មិនត្រូវអង្គុយឈរខ្ពស់ពេក អ្នកធំក្រឡេកមើលគុំគួន ទុកតៃថ្ងៃក្រោយរករឿងខ្លួន ជន្មាមាំមួនខូចបុណ្យស័ក្តិ ។ មិនត្រូវអង្គុយឈរពីមុខ មើលទៅចង្កូតចំនេត្រជាក់ អ្នកធំដៀងចិត្តពុំសូវស្ងែក ព្រោះអាក់មុខជាក់ប្រឹងសំឡឹង ។ មិនត្រូវអង្គុយឈរខាងក្រោយ ខ្នងលោកពេលណាយទីពុំដឹង ពេលាត្រូវមើលពោនថៃប្រឹង រេខ្លួនទទឹងទើបឃើញមុខ ។ ហៃអស់យុវជនប្រុសស្រី គួរចាំឃ្លាតឃ្លីចំណាំទុក ច្បាប់ទាំង ៦ ជាប្រមុខជាគ្រឿងនាំសុខពាំកុំភ្លេច ។ ទើបបានជាទីស្រឡាញ់ស្និទ្ធ អ្នកធំពេញចិត្តនេត្រមិនភ្លេច គង់ឲ្យលាភយសខ្ពស់ដូចពេជ្រ ប្រយោជន៍សម្រេចពីគោរព ។ ត្រូវធ្វើតាមរឿងឧបាសក ចេះស្គាល់ល្អគាត្រក់ជាគ្រឿងទប់ កាលគាត់ទៅគាល់ព្រះបមកព ដែនកិច្ចគោរពត្រូវតាមច្បាប់ ។

# រឿងឆត្តបាណិឧបាសក

សេចក្ដីថា: ក្នុងក្រុងសាវត្ថីមានបុរសម្នាក់ឈ្មោះ ឆត្តបាណិឧបាសក បានទៅបំរើព្រះសម្មាសម្ពុទ្ធអំពីព្រឹករួចហើយអង្គុយចាំស្ដាប់ធម៌ ។

សម័យនោះឯង ព្រះបាទបសេនទិកោសល ទ្រង់យាងទៅបំរើព្រះសម្មាសម្ពុទ្ធជាម្ចាស់ដែរ ។ ឆត្តបាណិឧបាសក ឃើញស្ដេចយាងមកដល់ជិតហើយ ក៏គិតថា: "អញគួរក្រោកទទួល ឬមិនគួរក្រោកទទួលទេ? ព្រោះអញកំពុងអង្គុយគាល់ព្រះពុទ្ធជាធំជាងស្ដេច កាលបើអញក្រោកទទួល ឈ្មោះថាសេចក្ដីមិនគួរដល់អញសោះ ស្ដេចនេះមុខជាទ្រង់ខ្ញាល់ដល់អញ ព្រោះតែមិនក្រោកទទួល បើទុកជាស្ដេចនេះទ្រង់ខ្ញាល់ក៏ដោយ គាត្នាអញមិនត្រូវក្រោក កាលបើអញក្រោកទទួលហើយ បានឈ្មោះថាអញជាអ្នកគោរពស្ដេច មិនឈ្មោះថាជាអ្នកគោរពដល់ព្រះពុទ្ធឡើយ" ហើយគាត់ក៏អង្គុយស្ងៀមទៅ" ។

ធម្មតាបណ្ឌិតបុរសកាលបើឃើញបុគ្គលណាមួយ អង្គុយក្នុងសំណាក់បុគ្គលដែលធំជាងខ្លួន គេមិនត្រូវខឹងចំពោះបុគ្គលនោះឡើយ ។

ឯព្រះបាទបសេនទិកោសល ទ្រង់ឃើញឆត្តបាណិឧបាសកនោះហើយ ក៏មានព្រះហឫទ័យទ្រង់ក្រោធ ហើយថ្វាយបង្គំព្រះសាស្ដារួចថយទៅអង្គុយក្នុងទីដ៏សមគួរ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ថ្លែងគុណរបស់ឧបាសកថា: មហាបពិត្រ ឧបាសកនេះ ជាអ្នកចេះព្រះត្រៃបិដក ឆ្លាត

ស្គាល់ហេតុ ដែលជាប្រយោជន៍ និងមិនមានប្រយោជន៍ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ មានព្រះទ័យជ្រះថ្លាដ៏ទន់ភ្លន់ ។

ថ្ងៃក្រោយព្រះបរមក្សត្រទ្រង់គង់លើប្រាសាទ ទតទៅឃើញធគ្គបាណ៌ឧបាសកនោះ កាន់ឆ័ត្រ ពាក់ស្បែកជើងដើរតាមមុខព្រះលាន ទ្រង់ត្រាស់ហៅឲ្យចូលទៅ ។ គាត់ក៏ដំឡោះឆ័ត្រ ដោះស្បែកជើងដើរចូលទៅ ហើយថ្វាយបង្គំថយទៅអង្គុយក្នុងទីដ៏សមគួរ ។

គ្រានោះ ស្ដេចទ្រង់សួរថា: "នែឧបាសក! ដូចម្ដេចក៏បានជាអ្នកដំឡោះឆ័ត្រ ដោះស្បែកជើងហើយដើរចូលមក" ។ គាត់ក៏ឆ្លើយថា: សូមទ្រង់ព្រះមេត្ដាប្រោស "ទូលព្រះបង្គំឮថា ព្រះអង្គទ្រង់មានព្រះរាជត្រាស់ហៅឲ្យចូលមក" ។ ស្ដេចទ្រង់សួរចំអកថា: "អ្នកទើបតែនឹងដឹងថាយើងជាស្ដេចក្នុងថ្ងៃនេះទេឬ?" ។

គាត់ឆ្លើយថា: "ទូលព្រះបង្គំជាខ្ញុំបានដឹងថាព្រះអង្គជាស្ដេចមកយូរណាស់ហើយ" ។ ស្ដេចបានត្រាស់ថា: "តើបើអ្នកដឹងថាយើងជាស្ដេច ហេតុអ្វីពីថ្ងៃមុនអ្នកអង្គុយជាមួយនឹងព្រះសម្មាសម្ពុទ្ធជាម្ចាស់ ឃើញយើងហើយក៏អ្នកមិនក្រោកឡើងទទួល?" ។ គាត់ឆ្លើយតបព្រះរាជឱង្ការថា: "សូមទ្រង់ព្រះមេត្ដាប្រោស ទូលព្រះបង្គំកំពុងអង្គុយក្នុងសំណាក់ព្រះពុទ្ធជាស្ដេចដ៏ប្រសើរ, ឃើញព្រះអង្គជាស្ដេចក្នុងប្រទេស ហើយក្រោកឡើង ឈ្មោះថាមិនមានសេចក្ដីគោរពក្នុងព្រះពុទ្ធជាម្ចាស់

ហេតុនោះ ទូលព្រះបង្គំជាខ្ញុំមិនហ៊ានក្រោកទទួលព្រះអង្គ" ។ ស្តេចមានព្រះរាជឱង្ការថា: "ណ្ហើយ យើងនេះយ៉ាងណាគេស្មេះបុះ! ។ល។

រឿងនេះហើយ សូមអស់លោក-អ្នក អ្នកយល់រៀបមើលគួរពិចារណាប្រើវិធីទទួលបដិសណ្ឋារៈព្រមទាំងស្គាល់ប្រមាណក្នុងបុគ្គលឲ្យដូចជាចក្ខុជាណ។ ព្រោះថានេះ ទើបឈ្មោះថាជាអ្នកស្គាល់បុគ្គលនេះស្មើនឹងបុគ្គលនោះ ឬក៏ស្គាល់ថាលើសជាងបុគ្គលនោះ ។ ។

ចប់ទោសដែលកើតអំពីអង្គុយ ឬឈរតែប៉ុណ្ណេះ ។

## លក្ខណៈជាគ្រឿងកំណត់មនុស្សអ្នកក្រោធ ៣ យ៉ាង

១ - បាសាណលេខូបមោ បុគ្គលអ្នកក្រោធដូចជាគំនូសថ្ម

២ - បឋវីលេខូបមោ បុគ្គលអ្នកក្រោធដូចជាគំនូសលើដី

៣ - ឧទកលេខូបមោ បុគ្គលអ្នកក្រោធដូចជាគំនូសទឹក ។

ទី ១ សេចក្ដីថា: បុគ្គលដែលក្រោធខឹងនឹងបុគ្គលណាមួយ មានបុត្រភរិយា ញាតិបងប្អូន ឬទាសកម្មករជាដើម ហើយក្រោធប្រកាន់ចិត្តតាំងព្យាបាទរហូតយ តាំងពីលើយវែលតែលែកបានទៅហោចភ្លេច ដូចជាគេយកពន្លាក ឬដែកមុតទៅដាប់ ឬឆ្លាក់ថ្មឲ្យជាគំនូសរហូត ស្នាមគំនូសថ្មនោះ ទុកណាជាមានខ្យល់ ឬទឹកធ្លាក់ចុះបោកបក់ត្រូវក៏

មិនកាចខឹងធ្វើឲ្យលុបរលាយស្នាមទៅវិញបានយ៉ាងណា សេចក្ដីក្រោធខឹងនឹងរលុបរលាយទៅយ៉ាងនោះ ។

ទី ២ បុគ្គលដែលក្រោធខឹងនឹងបុគ្គលណាមួយហើយ មិនបានប្រកួតប្រកាន់ចិត្តតាំងប្រទូស្តរ៉ាយសង្កត់ទុកយូរប៉ុន្មាន ឆាប់រសាយរលាយរលុបទៅវិញឆាប់ ដូចជាគេយកកំណាត់ឈើឬគេគូរមួយ ទៅគូសដែនដីឲ្យមានស្នាមគំនូសឡើង ស្នាមគំនូសនោះ កើតមានខ្យល់បក់ទឹកភ្លៀង ហូរធ្លាក់ចុះមកត្រូវ ក៏រលាយរលុបស្នាមនោះទៅវិញឆាប់ មិនតាំងនៅយូរប៉ុន្មានយ៉ាងណា សេចក្ដីក្រោធខឹងឆាប់រលុបរលាយទៅយ៉ាងនោះដែរ ។

ទី ៣ បុគ្គលដែលក្រោធខឹងនឹងបុគ្គលណាមួយហើយ មិនបានប្រកួតប្រកាន់ចិត្តតាំងប្រទូស្តរ៉ាយ ឆាប់រសាយរលាយរលុបបាត់ទៅ ១ រំពេចមិនសង្កត់ទុកផ្តាប់យូរឲ្យកន្លងពេលវេលាឡើយ ដូចជាគេយកកំណាត់ឈើឬគេគូរមួយទៅគូសទឹកឲ្យមានស្នាមគំនូសឡើង ក៏ឃើញតែស្នាម ១ រំពេចប៉ុណ្ណោះ ហើយបាត់ទៅវិញលាយដៃភ្លាម មិនបានតាំងនៅយ៉ាងយូរឡើយ ។

ក៏ត្រូវគន់គោលនិយម របស់បុគ្គលអ្នកក្រោធខឹងចំពោះទៅលើបុគ្គលដទៃឬគ្រូដទៃនោះៗ មានច្រើនយ៉ាង ។

ឯសេចក្ដី "ក្រោធ ឬ ហៅថា ទោសៈ" នោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រៀបធៀបនឹងអង្កត់ខ្មោចដោយព្រះពុទ្ធដីកាថា:

សេយ្យថាបិ ភិក្ខវេ ឆវាលាតំ ឧភតោ បទិត្តំ មជ្ឈេ គូថគតំ នេវ គាមេ កដ្ឋត្ថំ ផរតិ ន អរញ្ញេ កដ្ឋត្ថំ ផរតិ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។

សេចក្ដីថា: ម្នាលភិក្ខុទាំងឡាយ អង្កត់ខ្មោចដែលគេដុតខ្មោច ហើយមានឆេះទាំងសងខាងភ្លើងនេះ ត្រង់កណ្ដាលប្រឡាក់លាមក (អង្កត់ខ្មោចនោះឯង) ក៏មិនបានសម្រេចប្រយោជន៍ជាឧសដុតប្រើប្រាស់ក្នុងស្រុកផង មិនបានសម្រេចប្រយោជន៍ជាឧសក្នុងព្រៃផងយ៉ាងណា អថាគតពោលថា បុគ្គលអ្នកក្រោធខឹងនោះ ក៏មិនបានសម្រេចប្រយោជន៍ទាំងពួងក្នុងលោកនេះ ទាំងបរលោកខាងមុខយ៉ាងនោះដែរ ។

សេចក្ដីនេះ ស្រាយថា: បុគ្គលដែលក្រោធខឹងច្រើន មិនបានឈ្មោះថាជាអ្នកធ្វើតាមសាសនាព្រះដ៏មានភាគបានទេ មិនបានឈ្មោះថាជាអ្នកឈ្នះសង្គ្រាមដែលគេឯងត្រូវឈ្នះបានទេ មិនបានឈ្មោះថាជាអ្នកធ្វើធម៌ដែលជាសត្រូវចង់ធ្វើដល់ខ្លួនឯងឲ្យរលត់បានទេ គ្រាន់តែបានឈ្មោះថាជាអ្នកដូចគ្នានឹងអង្កត់ខ្មោចប៉ុណ្ណោះឯង ។

ក្នុងសម្បុរសទាំងឡាយចង់បៀតបៀនទោសៈដែលកើតឡើងអំពី "អញ្ញាន-កោបៈ" គឺជាសេចក្ដីក្រោធកើតឡើងខុសថែបទ្ទុបជំនឹងមិនគួរដល់

ហេតុនឹងវិធី ដូចក្រោមនេះទឹក-ភ្លើង-ខ្យល់-ត្រៀង-ផ្កា-ក្អែក-ត្រជាក់ជាដើមថា: “ទឹកជន់ឡើងខ្លាំងពេក ធ្វើស្រែចំការពុំបាន លិចស្រូវ រលួយស្រូវក្នុងស្រែ ពិបាកដំណាំពោត-សណ្ដែក-ល្ងជាដើម ឬក៏គ្មានទឹកជន់ឡើងមកទេ ខានធ្វើស្រែចំការ-ដាំពោត សណ្ដែក ល្ង-មិនកើត” មួយទៀត គួរចិត្តស្រែកជេរប្រទេចផ្ដាសាទឹកថា: ម្រាយអាទឹក! មុំបក៏មិនជន់ឡើង! ម៉ែវាទៅណាទៅ! ខានធ្វើស្រែចំការអស់! អាទឹក! ជន់ឡើងខ្លាំងពេក រកតែធ្វើស្រែមិនកើត! ស៊ីស្រែកទៅឲ្យដាច់” ក្រោធខឹងជេរដូច្នេះក៏មាន ។

ខ្លះខឹងនឹងភ្លើងឆេះផ្ទះសម្បែង បង្កាត់ជាំបាយមិនឆេះ ផ្ទុំមិនឆេះ ឆេះសំពត់អាវស្បៃ រលាកដៃជើង ស្ទុះក្រោកឡើងស្រែកជេរថា: “ម្រាយអាភ្លើងបានតែរលាកដៃជើង ឆេះសំពត់អាវ ត្រង់បង្កាត់ជាំបាយមិនឆាយឆេះទេ! ផ្ទុំក៏មិនឆេះ!” មិនតែជេរប៉ុណ្ណោះ ស្ទុះទៅបោចពេបភ្លើង យកទឹកជះសាចភ្លើងនោះថែមទៀត បែបនេះក៏មាន ។

ខ្លះខឹងនឹងខ្យល់ព្យុះផែលបោកបក់មកខ្លាំងពេក ដាលតែរលំផ្ទះសម្បែង រលើងដំបូលអស់ពៅ កើតសេចក្ដីក្ដៅក្រហាយស្រែកជេរម្រាយអាខ្យល់ថាព្យុះផល់ណាទៅទៀត! មិនដឹងជាក់លើផ្ទះសម្បែង ធ្លាក់បែកអំបោះអស់ហើយទេ! ម្រាយអាខ្យល់ បើបានជាខ្យល់ៗមិនឈប់! បង្ហិនបង្ហោច

ធានឈល់ថេសអ៊ី!" យ៉ាំងនេះក៏មានដែរ, បើថាជាក្រឡប់គ្មានខ្យល់បក់លំហើយខ្ទួនវិញ គេតែងសេចក្ដីក្ដៅស្រះក្រពះត់ទិកស្ទះបុះស្ទុះទៀងដោលក់លេដេរខ្យល់ទៀតថា: "ចុះខ្យល់ក៏ទៅណាអស់ទៅហេរ! ដុកមុំចក៏មិនខ្យល់មក។ ក្ដៅស្ទុះស្ទើរតែទីងស្លាប់ អាតាពាយ" យ៉ាងនេះក៏មាន ។

ខ្ទះខ្ទីងទីងភ្លៀងដែលកំពុងឹដផ៌ះហោះធ្លាក់ចុះមក ជោកជាំ ផែនដីហូរជោគជាក់ដូះសម្បែង រលំដំណាំក្នុងស្រុកភូមិ ធ្វើឲ្យគេស៊ីមិនកើតម្ហូមៅក្ដៅចិត្តស្រែកដេរភ្លៀងថា: "មីកភ្លៀងមិនឈប់មិនឈរសោះ! រកតែធ្វើការអ្វីមិនកើត រលំដំណាំ ធ្លាក់ដូះសម្បែងអស់ ចុះកាភ្លៀងមកឲ្យទុំភណៈហ្ន៎ង;" បើបែរជាក្រឡប់គ្មានភ្លៀងវិញ ខានធ្វើស្រែចំការដេរប្រទេចផ្ដាសាថា: 'អាភ្លៀងមុំចក៏មិនភ្លៀងមក! ការទៅភ្លៀងឲ្យមីកឯណាទៅ! ទីស្រែដំណាំដែលឯងធ្វើស្រែចំការ ក៏មិនភ្លៀងទេ! ការទៅភ្លៀងឲ្យដីដូនកឯណាផ្ដាសាទៅ" យ៉ាំងនេះក៏មាន ។ ជូនកាលរឹសក៏ងណាស់ មិនមានភ្លៀងធ្លាក់មកសោះ ដេរដំណាក់ហៅសាទៅកើតក្ដសមណព្រាហ្មណ៍ថា "ព្រោះពួកសមណព្រាហ្មណ៍ទាំងនេះឯងនាំគ្មានភ្លៀងធ្លាក់ចុះមកក្នុងដាំនេះ ឲ្យអាក្រមងំ" ដូរទៅលើសមណព្រាហ្មណ៍បែបនេះ ក៏មានខ្លះដែរ ។

(មានត)

## សេចក្ដីជូនដំណឹង

ទស្សនាវដ្ដី កម្ពុជសុរិយា ដែលពុទ្ធសាសនបណ្ឌិត្យកម្ពុជរដ្ឋ បានបោះពុម្ពផ្សាយរាល់ៗខែក្នុងឆ្នាំ ១៩៤៨ នេះ តើអស់លោកអ្នកអានពេញចិត្តហើយ ឬមួយគួរកែប្រែជួបម្ដេចខ្លះៗ មួយវិញទៀត ប្រសិនបើ អស់លោកមានរឿងរ៉ាវប្លែក ៗ ទាំងខាងផ្នែកគតិលោក ទាំងខាងផ្នែកគតិធម៌ ដែលមិនទាន់បានបោះពុម្ពផ្សាយ សូមលោកមេត្តាផ្ញើទៅបុះ យើងនឹងពិនិត្យមើល បើល្មមបុះផ្សាយបាន យើងនឹងបុះផ្សាយចែកញាតិរួមជាតិ អានមើលរាល់គ្នា ។ យើងសូមថ្លែង អំណរអរគុណអស់លោកទុកជាមុន ។

បណ្ណាធិការ